បោះពុម្ពនៅរោងពុម្ព ទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ១.៥០០ ច្បាប់

តម្លៃ ២៧៥០ រៀល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៧ លេខ ១៩ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៩៩

# រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រី រៀងរាល់សប្ដាហ៍

# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រម


១៧-៥-១៩៩៩ -ព្រះរាជក្រម នស/រកម/០៥៩៩/០២ ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងសហប្រតិបត្តិការ រវាងព្រះរាជាណាចក្រកម្ពុជា និង សហគមន៍អឺរ៉ុប ៨១៥


### ២-ព្រះរាជក្រឹត្យ


១៧-៥-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១០១ តែងតាំងឯកឧត្តម គន់ ថាន់ ជាទីប្រឹក្សារបស់ឯកឧត្តម ទុល ឡោះ ឧបនាយករដ្ឋមន្ត្រី ៨១៦

១៩-៥-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១០៣ តែងតាំងឯកឧត្តម ពិន ដាំ ជាទីប្រឹក្សាក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ៨១៧

១៩-៥-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១០៤ តែងតាំងឯកឧត្តម អ៊ូ ប៊ុនថន ឯកឧត្តម ជុំ គឹមអេង ជាទីប្រឹក្សាក្រសួងអប់រំ យុវជន និងកីឡា ៨១៨

១៩-៥-១៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១០៥ តែងតាំងឯកឧត្តម សៅ សាមុត ជាទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៨១៩

១៩-៥-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១០៦ តែងតាំង ឯកឧត្តម រស់ ធឿន ជាទីប្រឹក្សាក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង នីតិសម្បទា ៨១៩

១៩-៥-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១០៧ តែងតាំងឯកឧត្តម ឌុក ខុត្តអោ ជាទីប្រឹក្សាក្រសួងការពារជាតិ ៨២០

១៩-៥-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១០៨ តែងតាំងឯកឧត្តម ម៉ឺន ជារ៉ែត , ឯកឧត្តម នឹក ខ៊ុយ ជាទីប្រឹក្សាអមទីស្ដីការគណៈរដ្ឋមន្ត្រី ៨២១

១៩-៥-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១០៩ តែងតាំងឯកឧត្តម សៀង ហាក់ ជាទីប្រឹក្សាអមទីស្ដីការគណៈរដ្ឋមន្ត្រី ៨២២

២៥-៥-១៩៩៩ -ព្រះរាជក្រឹត្យនស/រកត/០៥៩៩/១១១ តែងតាំងឯកឧត្តម គួច សេងឆេង ជាទីប្រឹក្សាផ្ទាល់របស់សម្ដេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា ៨២៣

២២-៥-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១១៣ តែងតាំងឥស្សរជន ០៣ រូប ជាទីប្រឹក្សាផ្ទាល់ឯកឧត្តម ញឹក ប៊ុនឆៃ អនុប្រធានទី២ នៃព្រឹទ្ធសភា ៨២៣

## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


| | | |
|---|---|---|
| ១៧-៥-១៩៩៩ | -អនុក្រឹត្យលេខ ៥៤ អនក្រ.បក ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទ | ៨២៥ |
| ១៧-៥-១៩៩៩ | -អនុក្រឹត្យលេខ ៥៥ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មការរៀបចំទិវាមហោស្រពអង្គរ ឆ្នាំ ១៩៩៩- ២០០០ | ៨២៧ |
| ១៨-៥-១៩៩៩ | -អនុក្រឹត្យលេខ ៥៦ អនក្រ.បក ស្តីពីការផ្ទេរឥណទាន | ៨៣០ |
| ១៩-៥-១៩៩៩ | -អនុក្រឹត្យលេខ ៥៧ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាយោធា | ៨៣១ |
| ១៧-៥-១៩៩៩ | -អនុក្រឹត្យលេខ ១៥៦ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិ តែងតាំង និងផ្លាស់ប្តូរមុខងារ | ៨៣៣ |
| ១៨-៥-១៩៩៩ | -អនុក្រឹត្យលេខ ១៥៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៨៣៤ |
| ២១-៥-១៩៩៩ | -អនុក្រឹត្យលេខ ១៥៨ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ | ៨៣៥ |
| ២១-៥-១៩៩៩ | -អនុក្រឹត្យលេខ ១៥៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៨៣៦ |


### ២-សេចក្តីសំរេច


| | | |
|---|---|---|
| ១៧-៥-១៩៩៩ | -សេចក្តីសំរេចលេខ ៥២ សសរ ស្តីពីការបង្កើតគណៈកម្មការសំរាប់ពិនិត្យ និង ដោះស្រាយបាតុភាពដីធ្លីនៅ ខេត្តកំពង់ស្ពឺ | ៨៣៨ |
| ២២-៥-១៩៩៩ | -សេចក្តីសំរេចលេខ ៥៣ សសរ ស្តីពីការផ្ទេរសិទ្ធិ នៃរាជរដ្ឋាភិបាល | ៨៤០ |


### ៣-សេចក្តីប្រកាស


| | | |
|---|---|---|
| ២២-៥-១៩៩៩ | -សេចក្តីប្រកាសលេខ ០៣ ប្រក សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលដើម្បីជំរុញការដោះមីននៅក្នុងព្រះរាជាណាចក្រកម្ពុជា | ៨៤២ |


### ៤-សារាចរ


| | | |
|---|---|---|
| ២៦-៥-១៩៩៩ | -សារាចរលេខ ០៥ សរ ស្តីអំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងព្រះរាជាណាចក្រកម្ពុជា | ៨៤៩ |


### សារាចរណែនាំ


| | | |
|---|---|---|
| ២១-៥-១៩៩៩ | -សារាចរណែនាំលេខ ០៧ សរ ណន ស្តីពីការចាត់តាំងរៀបចំទិវាមហោ | |

## គ


ត្រាពអង្គរ ឆ្នាំ ១៩៩៩-២០០០ ៨៥៩

### III-ការងារបណ្ដាក្រសួង

#### ១-នីតិការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

##### ប្រកាស

១៧-៥-១៩៩៩ -ប្រកាសលេខ ៣៩៣ ប្រក.សហវ.៣៨ ស្ដីពីការកែប្រែសមាសភាពគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ៨៥៥

#### ២-នីតិការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

##### ប្រកាស

២១-៥-១៩៩៩ -ប្រកាសលេខ១៤៣៧ ពណ.បអព ៩៩ ស្ដីពីការចេញវិញ្ញាបនបត្រប្រភពដើមទំនិញ វក្កយបត្រ ពាណិជ្ជកម្ម និង អាជ្ញាប័ណ្ណនាំចេញ ចំពោះទំនិញសំលៀកបំពាក់សំរាប់នាំចេញ ៨៥៩

#### ៣-នីតិការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

##### ប្រកាស

២០-៥-១៩៩៩ -ប្រកាសលេខ ៩៩៤ ឧក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ស៊ិនប្ល៊ូ (ខេមបូឌា ) ឯិចស្ពែរេ លីមីធីត តំណាងដោយលោក MA BAOXING សញ្ជាតិ ចិន បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ នាំចេញ ៨៦៧

#### ៤-នីតិការរដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

##### ប្រកាស

១៨-៥-១៩៩៩ -ប្រកាសលេខ ២២ ប្រក ស្ដីពីការបញ្ចូលក្របខ័ណ្ឌមន្ត្រីរាជការ .៨៦៨

#### ៥-នីតិការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

##### ប្រកាស

១៧-៥-១៩៩៩ -ប្រកាសលេខ ៣៩២ អយក.ប្រក ស្ដីពីការបើកសាលាបឋមសិក្សា " ភ្នំត្រពាំង " ៨៧៨

១៧-៥-១៩៩៩ ប្រកាសលេខ ៣៩៣ អយក.ប្រក ស្ដីពីការបើកសាលាបឋមសិក្សា " វត្តជ័យខ្ពស់ " ៨៧៩

១៧-៥-១៩៩៩ ប្រកាសលេខ ៣៩៤ អយក.ប្រក ស្ដីពីការបើកសាលាបឋមសិក្សា"ស្ពាន

| | | |
|---|---|---|
| | ព្រាវ អេស ទី ស៊ី ” | ៨៨០ |
| ១៧-៥-១៩៩៩ | -ប្រកាសលេខ ៣៨៥ អយក.ប្រក ស្តីពីការផ្តល់គោលការណ៍ឲ្យសម្ព័ន្ធ “ វគ្គ ជំរុកខ្ពស់ ” មកជាគ្រឹះស្ថានឧត្តមសិក្សាពេញលក្ខណៈ | ៨៨១ |
| ១៧-៥-១៩៩៩ | -ប្រកាសលេខ ៣៨៦ អយក.ប្រក ស្តីពីការទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សា “ សមាគមអក្សរសាស្ត្រគ្រូខ្មែរ ” | ៨៨២ |
| ១៧-៥-១៩៩៩ | -ប្រកាសលេខ ៣៨៧ អយក.ប្រក ស្តីពីការផ្តល់គោលការណ៍ឲ្យសម្ព័ន្ធ “ ប៊ុន តែន គតបត្រពែក ” មកជាគ្រឹះស្ថានឧត្តមសិក្សាពេញលក្ខណៈ | ៨៨៤ |

## ៦-ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល

### ប្រកាស

| | | |
|---|---|---|
| ១៩-៥-១៩៩៩ | -ប្រកាសលេខ ១៩៣ អបស ស្តីពីការកំណត់តួនាទីភារកិច្ចរបស់ក្រុមចត្តាឡីស័ក នៅតាមច្រកព្រំដែន | ៨៨៥ |

## ៧-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

### សេចក្តីសំរេច

| | | |
|---|---|---|
| ២១-៥-១៩៩៩ | -សេចក្តីសំរេចលេខ ៥០២ សសរ.អគ.ព្រន ស្តីពីការបែងចែកនិស្សិតចំនួន ០៣ នាក់ ដែលទើបបញ្ចប់ការសិក្សាពីបរទេស | ៨៨៧ |

## ៨-ទីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

### ប្រកាស

| | | |
|---|---|---|
| ១៩-៥-១៩៩៩ | -ប្រកាសលេខ ៦៦ ប្រក.វវស.ក ស្តីពីការតែងតាំងមន្ត្រីរាជការមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ក្រុងប៉ៃលិន | ៨៨៩ |

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ១-ព្រះរាជក្រម

### ព្រះរាជក្រម នស/រកម/០៩៩៩/០២

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់ទតព្រះរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បានទ្រង់ទតព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្ម មាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ទតព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញទ្រង់ទតព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ទតព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់ទតព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងសហប្រតិបត្តិការ រវាងព្រះរាជាណាចក្រកម្ពុជា និងសហគមន៍អឺរ៉ុប ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

**មាត្រា ១ ._** អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងសហប្រតិបត្តិការ រវាងព្រះរាជាណាចក្រកម្ពុជា និងសហគមន៍អឺរ៉ុប ដែលធ្វើនៅទីក្រុង លុចហ្សំបួរ ថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៩៧ ហើយដែលមានអត្ថបទទាំងស្រុង ភ្ជាប់មកជាមួយនេះ ។

**មាត្រា ២ ._** រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

**មាត្រា ៣ ._** ច្បាប់នេះត្រូវបានប្រកាសទុកជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៩

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

**បាយយកសេចក្តីក្រាបបង្គំទូលថ្វាយ**
**សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ**
**នាយរដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

**បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី**
**ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
**ហត្ថលេខា**
**ហោ ណាំហុង**

★★★

## ២-ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១០១

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់ឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមការស្នើសុំរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

មាត្រា ១ ._ តែងតាំងឯកឧត្តម គង់ ថាន់ ជាទីប្រឹក្សារបស់ឯកឧត្តម តូល ឡោះ ឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

មាត្រា ២ ._ បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ ._ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ ._ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅសៀមរាប អង្គារថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

## ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១០៣

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់ឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ ._** តែងតាំងឯកឧត្តម **ពិន ដាំ** ជាទីប្រឹក្សាក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា ២ ._** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

**មាត្រា ៣ ._** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅសៀមរាប អង្គារថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៩

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

**ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១០៤**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ ._** តែងតាំងឥស្សរជនចំនួន០២រូប ជាទីប្រឹក្សាក្រសួងអប់រំយុវជន និងកីឡា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** :

១-ឯកឧត្តម **អ៊ុំ ម៉ុនថន**

២-ឯកឧត្តម **ជុំ គីមអេង**

**មាត្រា ២ ._** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

**មាត្រា ៣ ._** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅសៀមរាប អង្គារថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៩

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

★★★

## ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១០៥

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ .-** តែងតាំងឯកឧត្តម **សៅ សាមុត** ជាទីប្រឹក្សាក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ ។**

**មាត្រា ២ .-** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅសៀមរាប អង្គថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

## ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១០៦

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

មាត្រា ១ ._ តែងតាំងឯកឧត្តម រស់ ឡើន ជាទីប្រឹក្សាក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងនីតិសម្បទា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

មាត្រា ២ ._ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ ._ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅសៀមរាប អង្គរ,ថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៩

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

★★★

**ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១០៧**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

មាត្រា ១ ._ តែងតាំងឯកឧត្តម ឌុក ឡុងឆោ ជាទីប្រឹក្សាក្រសួងការពារជាតិ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

មាត្រា ២ ._ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា ៣ ._ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅសៀមរាប អង្គារថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

***

## ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១០៨

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

មាត្រា ១ ._ តែងតាំងឥស្សរជនចំនួន ០២ រូប ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ **អនុរដ្ឋលេខាធិការ :**

១- ឯកឧត្តម ម៉ែន ជាគេ ផ្នែកការងារអង្គការក្រៅរដ្ឋាភិបាល

២- ឯកឧត្តម នឹក ខ្ញុំយ ផ្នែកការងារវិនិយោគ

មាត្រា ២ ._ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

**មាត្រា ៣ ._** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅសៀមរាប អង្គារ៍ថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

**ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១០៩**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ ._** តែងតាំងឯកឧត្តម **សៀង ណាត់** ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី ផ្នែកប្រេងកាត និងឧស្ម័ន មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា ២ ._** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

**មាត្រា ៣ ._** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅសៀមរាប អង្គារ៍ថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

## ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១១១

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ឃើញលទ្ធផលឆ្នោតក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមសំណើ របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសេចក្តីត្រូវការការងារចាំបាច់

**ត្រាស់បង្គាប់**

**មាត្រា ១ .**_ តែងតាំងឯកឧត្តម គួច **សេងហេង** ជាទីប្រឹក្សាផ្ទាល់របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា ទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុមាន ឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា ២ .**_ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេច តាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .**_ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅសៀមរាប អង្គារថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

## ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១១៣

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្ម មាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៥ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៥៣ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណើរបស់ប្រធានព្រឹទ្ធសភា ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ១៩៩៩

**ត្រាស់បង្គាប់**

មាត្រា ១ ._ តែងតាំងឥស្សរជនចំនួន ០៣ រូប ជាទីប្រឹក្សាផ្ទាល់ឯកឧត្តម ញឹក ប៊ុនឆៃ អនុប្រធានទី២ នៃព្រឹទ្ធសភា ដែលមានរាយនាមដូចខាងក្រោមនេះ :

១-ឯកឧត្តម សំ គឹមហេង ទទួលបន្ទុក អភិវឌ្ឍន៍ជនបទ និងសង្គមកិច្ច មានឋានៈស្មើ រដ្ឋលេខាធិការ ។

២-ឯកឧត្តម នូ សុវណ្ណតី ទទួលបន្ទុកនយោបាយ សេដ្ឋកិច្ច អាកាសធាតុ និងការពារជាតិ មានឋានៈស្មើ រដ្ឋលេខាធិការ ។

៣-ឯកឧត្តម សោម ឧត្តរី ទទួលបន្ទុក នីតិកម្ម និងអប់រំ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ ._ ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ ._ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅសៀមរាប អង្គរថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ៤៥ អនក្រ.បក
### ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទ

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអង្គភាពសំរាប់សំរបសំរួលបញ្ហាកងទ័ពរំសាយ និងសមាហរណកម្ម ចូលក្នុងសង្គមជាតិ អតីតទាហានខ្មែរក្រហម

**សំរេច**

មាត្រា ១ ._ បង្កើតក្រុមប្រឹក្សា កំណែទម្រង់កងយោធពលខេមរភូមិន្ទ ដែលមានសមាសភាពដូចខាងក្រោម :

១-នាយឧត្តមសេនីយ៍ផ្កាយមាស៤ ទៀ បាញ់ ទេសរដ្ឋមន្ត្រីសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាសហប្រធាន

២-អ្នកឧកញ៉ា ស៊ីសុវត្ថិ សិរីរត្ន័ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាសហប្រធាន

៣-នាយឧត្តមសេនីយ៍ផ្កាយមាស៤ កែ គឹមយ៉ាន អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ជាអនុប្រធាន

៤-ឯកឧត្តម អ៊ុក រ៉ាប៊ុន រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអនុប្រធាន

៥-ឧត្តមសេនីយ៍ឯក មាស សុភា អគ្គមេបញ្ជាការរងនិងជាមេបញ្ជាការកងទ័ពជើងគោក ជាសមាជិក

៦-ឧត្តមសេនីយ៍ទោ មាស់ ឡើម ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី ជាសមាជិក

៧-ឧត្តមសេនីយ៍ត្រី អ៊ូ គឹមឡឿន អនុរដ្ឋលេខាធិការក្រសួងការពារជាតិ ជាសមាជិក

មាត្រា ២ ._ ក្រុមប្រឹក្សាកែទម្រង់កងយោធពលខេមរភូមិន្ទ មានភារកិច្ចដូចខាងក្រោម :

-ទទួលបន្ទុកលើកសំណើជូនឯកឧត្តម សហរដ្ឋមន្ត្រី ស្តីពីការកំណែទម្រង់សំខាន់ៗ ដែលទាក់ទងទៅ នឹងកំណែទម្រង់កងយោធពលខេមរភូមិន្ទ តាមទិសដៅរបស់ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ។

-ទទួលបន្ទុកសំរបសំរួលតាមដានជាអចិន្ត្រៃយ៍នូវកម្មវិធីកំណែទម្រង់

-ដើម្បីអនុវត្ត បេសកកម្មកែទម្រង់ កងយោធពលខេមរភូមិន្ទ ដូចបានចែងក្នុងមាត្រា ១ ក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទ ត្រូវបានជួយជាកំលាំងដោយគណៈកម្មការ អនុគណៈកម្មការរំសាយទ័ព នៃកងយោធពលខេមរភូមិន្ទ គណៈកម្មការ និងអនុគណៈកម្ម ការកំណែទម្រង់នៃកងយោធពលខេមរភូមិន្ទ ដែលនឹងត្រូវបានបង្កើតឡើងដោយប្រកាសរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និងក្រុមប្រឹក្សាបច្ចេកទេសស្រង់ស្ថិតិ និងធ្វើអត្តសញ្ញាណប័ណ្ណ ។

-ក្នុងការបំពេញបេសកកម្មដូចបានរៀបរាប់ខាងលើ ក្រុមប្រឹក្សាកំណែទម្រង់ នៃកងយោធពលខេមរភូមិន្ទមានភារកិច្ចជាក់ស្តែងដូចតទៅ :

-លើកសំណើស្តីពីការបង្កើត ឬការផ្លាស់ប្តូរគណៈកម្មការរំសាយទ័ព ។

-តម្រង់ទិសសកម្មភាពទាំងអស់របស់គណៈកម្មការរំសាយទ័ព ។ សំរបសំរួល និងត្រួតពិនិត្យមើលលទ្ធផលទាំងអស់របស់គណៈកម្មការ និងអនុគណៈកម្មការនីមួយៗ ។

-លើកសំណើជូនក្រសួងការពារជាតិ អំពីសំរោងឯកសារច្បាប់ និងបទបញ្ញត្តិទាក់ទងសំរាប់ដាក់អោយដំណើរការក្នុងការចុះត្រួតស្ថិតិ និងធ្វើអត្តសញ្ញាណប័ណ្ណ ។

មាត្រា ៣ ._ ត្រូវបង្កើតអគ្គលេខាធិការដ្ឋានទទួលបន្ទុក ការងារអចិន្ត្រៃយ៍ដែលមានសមាសភាពដូចខាងក្រោម :

១-ឧត្តមសេនីយ៍ទោ នួន ស៊ីផាន នាយរងសេនាធិការចំរុះ ជាអគ្គលេខាធិការ

២-ឧត្តមសេនីយ៍ទោ ជាំ ឫទ្ធិ នាយកទីចាត់ការការងារបុគ្គលិកអគ្គបញ្ជាការដ្ឋាន ជាអគ្គលេខាធិការរង

៣-ឧត្តមសេនីយ៍ទោ ពុត សំអោន នាយក នាយកដ្ឋានបុគ្គលិកក្រសួងការពារជាតិ ជាអគ្គលេខាធិការរង

៤-ឧត្តមសេនីយ៍ត្រី អ៊ួន លន នាយការិយាល័យទី១ កងទ័ពជើងគោក ជាសមាជិក

៥-វរនាវីទោ អ៊ិន ប៊ុនលី នាយការិយាល័យទី ១ កងទ័ពជើងទឹក ជាសមាជិក

៦-វរសេនីយ៍ទោ ញឹម សុវណ្ណ នាយការិយាល័យទី ១ កងទ័ពជើងអាកាស ជាសមាជិក

៧-វរសេនីយ៍ទោ លី នី នាយការិយាល័យទី ១ កងរាជអាវុធហត្ថ ជាសមាជិក

មាត្រា ៤ ._ អគ្គលេខាធិការដ្ឋាន ទទួលបន្ទុកធ្វើជាសេនាធិការផ្ទាល់ របស់ក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទ ហើយមានភារកិច្ចជាក់ស្តែងដូចតទៅ :

- ស្រាវជ្រាវ ពិចារណា និងលើកយោបល់ ស្តីពីការកែទម្រង់ ជូនក្រុមប្រឹក្សាកំណែទម្រង់ កងយោធពលខេមរភូមិន្ទ ។
- ត្រួតពិនិត្យផែនការ និងដំណើរការងារត្រួតស្ថិតិ និងធ្វើអត្តសញ្ញាណប័ណ្ណ ដើម្បីរំលឹការងាររំសាយទ័ព ។
- ដឹកនាំដំណើរការកម្មវិធីរំសាយទ័ព និងដំណើរគណៈកម្មការ អនុគណៈកម្មការរំសាយទ័ពអោយដំណើរការតាមផែនការកំណត់ ដោះស្រាយរាល់សំណើរបស់គណៈកម្មការ ដែលជួបការលំបាក ។
- តាមដានវាយតំលៃការងារអនុវត្ត ផែនការរបស់អនុគណៈកម្មការ ធ្វើអោយមានប្រសិទ្ធភាពល្អប្រសើរក្នុងការដំណើរការរំសាយទ័ព ។

មាត្រា ៥ ._ ក្រុមប្រឹក្សាកំណែទម្រង់ កងយោធពលខេមរភូមិន្ទ កំណត់របៀបវារៈនៃការប្រជុំនានា ដឹកនាំពិភាក្សា និង កំណត់ភាពវិធានការ និងសេចក្តីសំរេចទាំងអស់ ដែលពាក់ព័ន្ធ ។

-សមាជិកទាំងអស់ត្រូវចូលរួមប្រជុំការងារតាមការអញ្ជើញរបស់ សហប្រធាន ក្រុមប្រឹក្សាកំណែទំរង់កងយោធពលខេមរភូមិន្ទ ។

ការរៀបចំការប្រជុំទាំងឡាយរបស់ក្រុមប្រឹក្សាកំណែទំរង់កងយោធពលខេមរភូមិន្ទ និងការតាមដានការអនុវត្តនូវផែនការគោលគំនិតណែនាំទាំងអស់របស់ខ្លួន ត្រូវបានធានាដោយអគ្គលេខាធិការដ្ឋានទទួលបន្ទុកការងារអតិផ្តេរ ។

មាត្រា ៦ ._ រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៧ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ៤៥ អនក្រ.បក**

**ស្តីពីការបង្កើតគណៈកម្មការរៀបចំទិវា**

**មហោស្រពអង្គរ ឆ្នាំ១៩៩៩-២០០០**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌
- យោងតាមការចាំបាច់នៃការអនុវត្តភាពបើកឆ្នាំសន្តិភាព ទេសចរណ៍ ឆ្លងដំណាច់សតវត្សទី ២០

**សំរេច**

មាត្រា ១ ._ បង្កើតគណៈកម្មការរៀបចំទិវាមហោស្រពអង្គរឆ្នាំ ១៩៩៩-២០០០ មួយដែលមានសមាសភាពដូចតទៅ :

១-ឯកឧត្តម ស៊ុំ ម៉ានិត រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជាប្រធាន

២-ឯកឧត្តម មិន ឃិន រដ្ឋលេខាធិការក្រសួងព្រះបរមរាជវាំង ជាអនុប្រធាន

៣-ឯកឧត្តម ម៉ែន យ៉េត រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាអនុប្រធាន

៤-ឯកឧត្តម ថោង ខុន រដ្ឋលេខាធិការក្រសួងទេសចរណ៍ ជាអនុប្រធាន

៥-ឯកឧត្តម គង់ វិបុល រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក

៦-ឯកឧត្តមអ៊ុង គឹមអេន រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក

៧-ឯកឧត្តម អ៊ុំ ដារ៉ាវុឌ្ឍ រដ្ឋលេខាធិការក្រសួងព័ត៌មាន ជាសមាជិក

៨-ឯកឧត្តម ត្រាំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាសមាជិក

៩-ឯកឧត្តម ចាប ញ៉ុលីវុធ អភិបាលខេត្តសៀមរាប ជាសមាជិក

១០-ឯកឧត្តម សេខ តុង អភិបាលរងរាជធានីភ្នំពេញ ជាសមាជិក

១១-ឯកឧត្តម កែវ សាផល អនុរដ្ឋលេខាធិការអាកាសចរស៊ីវិល ជាសមាជិក

១២-ឯកឧត្តម ស៊ីង គង់ អគ្គនាយករងអាជ្ញាធរអប្សរា ជាសមាជិក

១៣-ឯកឧត្តម ប៉ាន់ ចន្ត្រា ប្រធានក្រុមហ៊ុនអាកាសចរភូមិន្ទកម្ពុជា ជាសមាជិក

១៤-លោក ឆែម គឹមហ៊ាង អគ្គនាយករងក្រសួងសាធារណការនិងដឹកជញ្ជូន ជាសមាជិក

១៥-លោកឧត្តមសេនីយ៍ ស៊ឹម សុផល ប្រធាននាយកដ្ឋានអង្គរក្សក្រសួងមហាផ្ទៃ ជាសមាជិក

១៦-លោក ខៀវ ថាវិកា ប្រធាននាយកដ្ឋានព័ត៌មានទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

មាត្រា ២ ._ ឆ្លងតាមរយៈទិវាមហោស្រពអង្គរឆ្នាំ ១៩៩៩ -២០០០ គណៈកម្មការនេះមានបេសកកម្មបង្ហាញជូន

ទស្សនារម្មណ៍ជាតិ និង អន្តរជាតិនូវ :

-អត្តសញ្ញាណជាតិខ្មែរតំណវង្សពីអង្គរ

-វប្បធម៌ អារ្យធម៌ដ៏រុងរោចន៍នាសម័យអង្គរ ផ្សារភ្ជាប់និងគោលនយោបាយរបស់រាជរដ្ឋាភិបាល នាបច្ចុប្បន្នក្នុងជំហរលើកកំពស់ :

ក-ការពង្រឹងសន្តិភាព

ខ-ផ្សះផ្សារជាតិ និងបង្រួបបង្រួមជាតិ

គ-សាមគ្គីធម៌ជាតិ និងអន្តរជាតិ

ឃ-ការស្តារវិរភាព កិត្តិយស និងសីលធម៌រស់នៅថ្លៃថ្នូររបស់ប្រជាពលរដ្ឋខ្មែរ

ង-តាមរូបភាព និងខ្លឹមសារនៃទស្សនីយភាពប្រែក្លាយទិវាមហោស្រពនេះអោយទៅជាព្រឹត្តិការណ៍ ប្រវត្តិសាស្ត្រពិភពលោកមួយសំដៅបំបាត់រាល់ការបង្អាប់បង្អួចកេរ្តិ៍ឈ្មោះខ្មែរពីសំណាក់បរទេស ក្នុងរយៈពេលកន្លងមកដោយប្តេជ្ញាទទួលខុសត្រូវវាសនាខ្លួនឯងនៅថ្ងៃអនាគត ។

មាត្រា ៣ ._ ដើម្បីសំរេចនូវបេសកកម្មខាងលើនេះ គណៈកម្មការរៀបចំទិវាមហោស្រពអង្គរឆ្នាំ ១៩៩៩-២០០០ មានភារកិច្ច ដូចតទៅ ៖

-បើកអង្គប្រជុំជាញឹកញាប់ដើម្បីពិភាក្សាពិគ្រោះយោបល់ និងបែងចែកភារកិច្ចដែលពាក់ព័ន្ធនឹង ព្រឹត្តិការណ៍នេះជូនសមាជិកទទួលខុសត្រូវរៀងៗខ្លួន

-ធ្វើសេចក្តីណែនាំស្តីពីការប្រារព្ធទិវាមហោស្រពឆ្នាំ ១៩៩៩-២០០០

-រៀបចំតាំងប្រធានបទ និមិត្តសញ្ញា រូបភាពបដិមាអោយទិវាមហោស្រពនេះ

-បង្កើតអនុគណៈកម្មការមួយចំនួនដើម្បីប្រគល់ភារកិច្ចដោយឡែកតាមភាពចាំបាច់

-តាមដានត្រួតពិនិត្យ កែសម្រួលជាជំហានៗ នូវរាល់សកម្មភាពរបស់ផ្នែកនីមួយៗ

-បំផុស និងអំពាវនាវគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ ប្រជាជន អ្នកមានជន សប្បុរសជន ដើម្បីជួយ ឧបត្ថម្ភគាំទ្រចំពោះទិវាមហោស្រពនេះ

-បំផុសអោយអ្នកមានជន ទេសចរជាតិ និង អន្តរជាតិចូលរួមក្នុងទិវាមហោស្រពនេះ អោយបានកុះករ

-ធ្វើវេទិកាកម្មអប់រំដល់ មន្ត្រីរាជការ នគរបាល កងទ័ព សិស្ស និស្សិត ប្រជាពលរដ្ឋគ្រប់ស្រទាប់ និង ព្រះសង្ឃនៅទូទាំងព្រះរាជាណាចក្រកម្ពុជា អោយជួយជ្រោងខ្ពស់ទិវាមហោស្រពប្រវត្តិសាស្ត្រនេះ

-ផ្សព្វផ្សាយ និងអំពាវនាវចំពោះសិប្បករខ្មែរអោយខិតខំសាំងស្នាដៃ ផលិតនូវវត្ថុសិល្បៈពាក់ព័ន្ធនឹងវប្បធម៌ អារ្យធម៌អង្គរជាពិសេស ប្រជាពលរដ្ឋ ខេត្តសៀមរាបទាំងមូល ដើម្បីលក់យកកំរៃនៅអំឡុងពេលប្រព្រឹត្តទៅនៃមហោស្រពនោះ

-ត្រៀមលក្ខណៈរៀបចំទីកន្លែងមុខប្រាសាទអង្គរវត្ត ដើម្បីសំដែង និងប្រារព្ធពិធី

-រកគ្រប់លទ្ធភាពបើកប្រាសាទមួយចំនួនទៀត ដូចជាទីលានជល់ដំរី និងស្រះស្រង់ ជាដើម សំរាប់ធ្វើទិទស្សន៍អំពីផ្លាស់សន្តិភាព ទេសចរណ៍ ចំពោះមជ្ឈដ្ឋានជាតិ និងអន្តរជាតិ

មាត្រា ៨ ._ កំណត់យកថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៩ ជាថ្ងៃពិធីបើកមហោស្រព ( ថ្ងៃចូលបុណ្យ )

-ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៩៩ ជាទិវាប្រកាស បិទ / បើកសតវត្ស និង ឆ្នាំ សន្តិភាព- ទេសចរណ៍ ដោយ **សម្តេចនាយករដ្ឋមន្ត្រី**

-និងថ្ងៃទី ០១ ខែមករា ឆ្នាំ២០០០ ជាថ្ងៃបិទមហោស្រព ។

មាត្រា ៩ ._ គណៈកម្មការជាតិរៀបចំទិវាមហោស្រព ឆ្នាំ១៩៩៩-២០០០ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ១០ . រាល់បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយ នឹងអនុក្រឹត្យនេះជាពិសេស អនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ១១ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សាលាក្រុងភ្នំពេញ គណៈកម្មការរៀបចំបុណ្យជាតិ និងអន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

អាជ្ញាធរអប្សរា និងស្ថាប័នពាក់ព័ន្ធព្រមទាំង សាមីជនដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៤៦ អនក្រ.បក

## ស្តីពីការផ្ទេរឥណទាន

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៨ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម នរ/រកម/០១៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការបែងចែកឥណទានថវិកា ចំណាយតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការផ្ទេរចំណូល និង ផ្ទេរឥណទានថវិកា សំរាប់ក្រសួងស្ថាប័នថ្មី

- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ .**_ ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ១.០០០ លានរៀល ( មួយពាន់លានរៀល ) ពីជំពូក ៥០ ( ចំណាយផ្សេងៗ ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៣០ ( អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច ) របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩ ។

**មាត្រា ២ .**_ ឥណទានថវិកាក្នុងមាត្រា ១ ខាងលើត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់ផ្តល់ជូនមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ។

**មាត្រា ៣ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**ហ៊ុន សែន**

**បានជំរាបជូន**
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា
រដ្ឋមន្ត្រីស្តីទី
**ហត្ថលេខា និងត្រា**
**អ៊ុក រ៉ាប៊ុន**

★★★

## អនុក្រឹត្យលេខ ៤៧ អនក្រ.បក
## ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រុមប្រឹក្សាយោធា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

- បានការឯកភាពពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ ១៩៩៩

**សំរេច**

**មាត្រា ១ .**_ បង្កើតក្រុមប្រឹក្សាយោធាមួយ ដោយអនុលោមតាមមាត្រាទី ២ នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ ក្រុមប្រឹក្សាយោធាត្រូវបានបង្កើតឡើងនៅក្រសួងការពារជាតិ ហើយដែលមានសមាសភាព :

- រដ្ឋមន្ត្រីក្រសួងការពារជាតិ ប្រធាន
- អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អនុប្រធាន
- នាយទាហានថ្នាក់ឧត្តមសេនីយ៍មួយរូបៗ តំណាងកងទ័ពជើងគោក កងទ័ពជើងអាកាស កងទ័ពជើងទឹក និងកងរាជអាវុធហត្ថ សមាជិក
- នាយទាហានថ្នាក់ឧត្តមសេនីយ៍មួយរូបៗ តំណាងអោយអគ្គនាយកដ្ឋានទាំងពីរ នៃក្រសួងការពារជាតិ សមាជិក
- នាយទាហានថ្នាក់ឧត្តមសេនីយ៍មួយរូបៗ តំណាងអោយស្ថាប័ន អធិការកិច្ច អយ្យការយោធា តុលាការយោធា នៃក្រសួងការពារជាតិ សមាជិក
- នាយទាហានមួយរូបៗ តំណាងអោយគ្រប់យោធភូមិភាគ និងគ្រប់កងពល សមាជិក
- នាយក នាយកដ្ឋានបុគ្គលិក ក្រសួងការពារជាតិ លេខាធិការ
- នាយកទីចាត់ការបុគ្គលិក អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ លេខាធិការរង

**មាត្រា ២ .**_ ក្រុមប្រឹក្សាយោធានេះ មានភារកិច្ចពិនិត្យ សិក្សា ពិចារណា ដើម្បីរៀបចំសំណើរាល់លិខិតបទដ្ឋានទាំងឡាយដែលទាក់ទងទៅនឹងបទដ្ឋានយោធា អោយបានសមស្របទៅនឹងច្បាប់ ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ មុននឹងផ្ញើជូនទៅគណៈរដ្ឋមន្ត្រី សំរេច ។

**មាត្រា ៣ .**_ ក្រុមប្រឹក្សាយោធា ត្រូវប្រជុំពិនិត្យស្រាវជ្រាវ និងប្រជុំពេញអង្គ :

- ការប្រជុំពិនិត្យស្រាវជ្រាវប្រព្រឹត្តទៅក្រោមអធិបតីភាពនៃតំណាងរដ្ឋមន្ត្រីក្រសួងការពារជាតិ ។
- ការប្រជុំពេញអង្គ ដើម្បីធ្វើសេចក្តីសំរេច ប្រព្រឹត្តទៅក្រោមអធិបតីភាពនៃរដ្ឋមន្ត្រីក្រសួងការពារជាតិ ។

**មាត្រា ៤ .**_ ក្រុមប្រឹក្សាយោធានេះ ត្រូវចូលរួមប្រជុំតាមការកំណត់របស់ប្រធាន ។

- ការប្រព្រឹត្តិទៅ នឹងការតែងតាំងសមាសភាពនៃក្រុមប្រឹក្សាយោធា ដូចមានចែងក្នុងមាត្រា១ នៃអនុក្រឹត្យនេះ ជាភារកិច្ចរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ។

មាត្រា ៥ .- ក្នុងករណីក្រសួងការពារជាតិត្រូវដឹកនាំដោយសហរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាសហប្រធាននៃក្រុមប្រឹក្សាយោធានេះ ។

មាត្រា ៦ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ទៀ បាញ់ ស៊ីសុវត្ថិ សិរីវុទ្ធ

★★★

## អនុក្រឹត្យលេខ ១៤៦ អនក្រ.តត

## ស្តីពីការតម្លើងឋានន្តរសក្តិ តែងតាំង និងផ្លាស់ប្តូរមុខងារ

***

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សំរេច

មាត្រា ១ .- ត្រូវបានតម្លើងឋានន្តរសក្តិ តែងតាំង និងផ្លាស់ប្តូរមុខងារ អាយុធមន្ត្រី ដែលមានរាយនាមដូចខាងក្រោម ៖

**ក-តម្លើងឋានន្តរសក្តិជាវរសេនីយឯក :**

១-លោកវរសេនីយទោ **ស៊ុន ម៉ុនសាត់** អត្តលេខ ០០១១២៣ នាយការិយាល័យគតិយុត្តនិងព្រហ្មទណ្ឌ កងរាជអាវុធហត្ថលើផ្ទៃប្រទេស បច្ចុប្បន្នជានាយសេនាធិការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេស

២-លោកវរសេនីយទោ **ដួង សារិន** អត្តលេខ ០០២៥៥៤ នាយការិយាល័យប្រតិបត្តិការកងរាជអាវុធហត្ថលើផ្ទៃប្រទេស បច្ចុប្បន្នជានាយកកងពលលេកព្រឹកព្រើន កងរាជអាវុធហត្ថលើផ្ទៃប្រទេស។

**ខ-តែងតាំង និងផ្លាស់ប្តូរមុខងារ :**

១-លោកវរសេនីយឯក **អ៊ិត សាឯម** អត្តលេខ ០០០៩១៥ ជំនួយការទីប្រឹក្សា សម្តេចនាយករដ្ឋមន្ត្រី បច្ចុប្បន្នជានាយការិយាល័យ ប្រតិបត្តិការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ។

២-លោកវរសេនីយឯក **នូ វណ្ណះ** អត្តលេខ ០០៣០៦ នាយសេនាធិការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេស បច្ចុប្បន្នជានាយទាហានរង់ចាំការងារ ទីចាត់ការការងារបុគ្គលិកអគ្គបញ្ជាការដ្ឋាន ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែតុលា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ១៤៧ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**មាត្រា ១.-** តែងតាំងមន្ត្រី បម្រើបេសកកម្មជាជំនួយការរបស់ ឯកឧត្តម តូច ឡោះ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា មានឋានៈស្មើប្រធាននាយកដ្ឋានដែលមានរាយនាមដូចខាងក្រោម ៖

១-លោក សេខ ប៊ុនធឿន

២-លោក ស៊ាត ម៉ុល

៣-លោក យ៉ោក ម៉ាច់

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តតាមអនុក្រឹត្យនេះឱ្យមាន ប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៨ ខែឧសភា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ១៤៨ អនក្រ.តត

## ស្តីពីការតម្លើងឋានន្តរសក្តិនាយឧត្តមសេនីយ៍ជាតិ

★★★

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១ .-** តម្លើងឋានន្តរសក្តិថ្នាក់ វរសេនីយ៍ឯក ជូនលោក **ជា អ៊ាខេង** ជំនួយការឯកឧត្តម **យូ ស៊ុនឡុង** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ១៤៩ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- **បានឃើញ**រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- **បានឃើញ**ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- **បានឃើញ**ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- **បានឃើញ**អនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- យោងតាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

សំរេច

មាត្រា ១ ._ ត្រូវបានតែងតាំងមន្ត្រីរាជការ ដែលមានរាយនាមដូចខាងក្រោម :

១-លោក ឆន ណារិន ជាប្រធាននាយកដ្ឋានវិភាគគំរោង និងការលើកទឹកចិត្ត នៃគណៈកម្មាធិការវិនិយោគកម្ពុជា " ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា " ។

២-លោក ហ៊ិន ថុរ៉ាក់ស៊ី ជាប្រធាននាយកដ្ឋានត្រួតពិនិត្យ និងតាមដានគំរោងវិនិយោគ នៃ គណៈ-កម្មាធិ ការវិនិយោគកម្ពុជា " ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

៣-លោក អន សុផាណារ៉ា ជាប្រធាននាយកដ្ឋាននីតិវិធី និងច្បាប់វិនិយោគ នៃគណៈកម្មាធិការវិនិយោគ កម្ពុជា " ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា " ។

៤-លោក មុខ ម៉ិនហួន ជាប្រធាននាយកដ្ឋានវិភាគប្រមូលសាស្ត្រនៃការវិនិយោគឯកជនបន្ថែមលើភារកិច្ចវាយតំលៃផ្នែកសំណង់ នៃគណៈកម្មាធិការវិនិយោគកម្ពុជា " ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា " ។

៥-លោក ជា ឧត្តី ជាប្រធាននាយកដ្ឋានទំនាក់ទំនងសាធារណៈ និងការជំរុញគំរោងវិនិយោគឯកជន នៃគណៈកម្មាធិការវិនិយោគកម្ពុជា "ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា"។

៦-លោកស្រី ម៉ៅ ណារ៉ា ជាប្រធាននាយកដ្ឋានសំរបសំរួលកិច្ចការអន្តរក្រសួង នៃគណៈកម្មាធិការវិនិយោគកម្ពុជា " ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា " ។

មាត្រា ២ ._ បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តន៍អនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី២១ ខែឧសភា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## ២-សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៩

### សេចក្តីសំរេចលេខ ៤២ សសរ

### ស្តីពីការបង្កើតគណៈកម្មការសំរាប់ពិនិត្យ និង ដោះស្រាយបាតុភាពបញ្ហាដី នៅខេត្តកំពង់ស្ពឺ

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការចាំបាច់ និងតម្រូវការរបស់រាជរដ្ឋាភិបាល

### សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការសំរាប់ដោះស្រាយបាតុភាពបញ្ហាដី នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ដែលមានសមាសភាពដូចខាងក្រោម ៖

១-ឯកឧត្តម ឧត្តមសេនីយ៍ទោ កែវ គាំ ប្រធានអធិការកិច្ច ក្រសួងការពារជាតិ ប្រធាន

២-ឯកឧត្តម យឹម សុខុម អភិបាលរងទី ១ ខេត្តកំពង់ស្ពឺ អនុប្រធាន

៣-ឯកឧត្តម ឧត្តមសេនីយ៍ទោ នុំ សំបុល ប្រធានអធិការកិច្ច អគ្គសេនាធិការ ក.ប.ខ.ភ.ម អនុប្រធាន

៤-ឯកឧត្តម ឧត្តមសេនីយ៍ទោ ស៊ិន ឌី មេបញ្ជាការរង កងទ័ពជើងគោក សមាជិក

៥-ឯកឧត្តម ថៃ ចាន់រិទ្ធ អគ្គនាយករង ក្រសួងទំនាក់ទំនងសភា និង អធិការកិច្ច សមាជិក

៦-ឯកឧត្តម ឧត្តមសេនីយ៍ទោ ឡាញ់ តៅ មេបញ្ជាការកងរាជអាវុធហត្ថ នៃអគ្គបញ្ជាការ សមាជិក

៧-លោក គុល ទិរក្ស ប្រធានអធិការដ្ឋាន កិច្ចការនយោបាយ រដ្ឋបាល ក្រសួងមហាផ្ទៃ សមាជិក

៨-លោក សួន ស៊ីផាត ប្រធានការិយាល័យ ត្រួតពិនិត្យនៃនាយកដ្ឋានសុរិយោដី ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ........................................... សមាជិក

៩-លោក សត្យា ឱុច អភិបាលស្រុក ភ្នំស្រួច .................................... សមាជិក

១០-លោក គង់ មុ មេឃុំ តាំងស្យា .................................... សមាជិក

១១-លោក ឆាន់ ឈឿន តំណាងប្រជាជនភូមិក្អែកពង .................................... សមាជិក

១២-លោក ហែម ឆាយ តំណាងប្រជាជនភូមិក្អែកពង .................................... សមាជិក

**ប្រការ ២ :** គណៈកម្មការនេះ មានភារកិច្ច ៖

-ចុះស្រាវជ្រាវ និងរៀបចំវិធានការដោះស្រាយអោយមានប្រសិទ្ធភាពនូវរាល់វិបត្តិភាព ដែលកើតឡើងនៅតំបន់ អា.គេ.អ៊ូ ( មជ្ឈមណ្ឌលបាញ់ចំរុះស្វ័យប្រវត្តិ ) ស្ថិតនៅក្នុង ឃុំតាំងស្យា ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ និងបន្តស្រាវជ្រាវរៀបចំវិធានការ ដោះស្រាយវិបត្តិភាពបញ្ហាដី នៅកន្លែងផ្សេងៗទៀតក្នុងខេត្ត កំពង់ស្ពឺ ។

-ធ្វើរបាយការណ៍អំពីលទ្ធផលដោះស្រាយបាន ក្នុងរយៈពេលសមស្របត្រូវរៀបចំជូនរាជរដ្ឋាភិបាលសំរេច ។

**ប្រការ ៣ :** សមាជិកនៃគណៈកម្មការទាំងអស់ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។

-គណៈកម្មការនេះ មានសិទ្ធិប្រើត្រាស់ត្រា របស់ក្រសួងការពារជាតិ ដើម្បីសំរួលការងារ ។

**ប្រការ ៤ :** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គបញ្ជាការកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងសភានិងអធិការកិច្ច រដ្ឋមន្ត្រីក្រសួង រៀបចំដែនដីនគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាល ខេត្តកំពង់ស្ពឺ និង ឯកឧត្តមអស់លោក ដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តី សំរេចនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ស ខេង**

★★★

រាជធានីភ្នំពេញ,ថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៩

**សេចក្តីសំរេចលេខ ៤៣ សសរ**

**ស្តីពីការផ្ទេរសិទ្ធិ នៃរាជរដ្ឋាភិបាល**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ ១ :** ផ្ទេរសិទ្ធិជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជា នាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាល ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅបំពេញបេសកកម្ម នៅក្រៅប្រទេស ចាប់ពីថ្ងៃទី ២៤ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់សម្តេចនាយករដ្ឋមន្ត្រីអញ្ជើញវិលត្រឡប់មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នប្រតិភូរាជរដ្ឋាភិបាល អភិបាល ខេត្ត-ក្រុង និង ឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

រាជធានីភ្នំពេញ,ថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៩

# ៣-សេចក្តីប្រកាស

## សេចក្តីប្រកាសលេខ ០៣ ប្រក

## សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល ដើម្បី

## ជំរុញការដោះមីននៅក្នុងព្រះរាជាណាចក្រកម្ពុជា

***

១. រាជរដ្ឋាភិបាលប្តេជ្ញាជំរុញការដោះមីននៅកម្ពុជា ឲ្យមានប្រសិទ្ធភាពខ្ពស់យ៉ាងឆាប់រហ័សបំផុត ដើម្បីរំដោះផ្ទៃដីមកជូនប្រជាពលរដ្ឋ ដែលត្រូវការដីធ្លីជាចាំបាច់សំរាប់សាងសង់លំនៅដ្ឋានធ្វើកសិកម្ម បង្កបង្កើនផល និងកសាងហេដ្ឋារចនាសម្ព័ន្ធផ្នែកសេដ្ឋកិច្ច និង សង្គមកិច្ច តាមផែនការស្តារ និង អភិវឌ្ឍន៍ជាតិ ។

២. រាជរដ្ឋាភិបាលបានសំរេចផ្តល់ថវិកា ដែលបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភារួចហើយ ចំនួនទឹកប្រាក់ប្រាំពីរពាន់លានរៀល ( ៧.០០០.០០០.០០០ ) ដល់មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ( CMAC ) ដើម្បីជាការរួមចំណែករបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងការខំប្រឹងប្រែងរួមជាមួយសហគមន៍អន្តរជាតិក្នុងការបោសសំអាតមីន ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធានាផ្តល់ថវិកា ដល់មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ( CMAC ) ឲ្យបានទាន់ពេលវេលា និងគ្រប់ចំនួនតាមតំរោងតំរូវការថវិកាដែល ( CMAC ) បានលើកឡើង ។

៣. រាជរដ្ឋាភិបាល បានស្នើតែងតាំងក្រុមប្រឹក្សាភិបាលថ្មី ដែលមាន ឯកឧត្តម **អៀង ម៉ូលី** ជាប្រធាន និងមានក្រុមសង្កេតការណ៍ចូលរួមផង ហើយសូមគាំទ្រចំពោះសកម្មភាព និង សេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល ដើម្បីឲ្យកិច្ចប្រតិបត្តិការដោះមីនបានប្រព្រឹត្តទៅដោយប្រសិទ្ធភាពឆាប់រហ័ស ដែលមានការទទួលខុសត្រូវ និងមានតម្លាភាពជាអាទិ៍ ៖ ការកែទំរង់ក្នុងការគ្រប់គ្រង ការកាត់បន្ថយការងារឲ្យទៅក្នុងមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ( CMAC ) ការដាក់បញ្ចូលកិច្ចប្រតិបត្តិការដោះមីននៅក្នុងផែនការអភិវឌ្ឍន៍ជាតិ កសាងច្បាប់ បញ្ញត្តិទាំងឡាយ ស្តីពីការគ្រប់គ្រងកាន់កាប់ដីដែលដោះមីនរួច ការរៀបចំផែនការដោះមីន សំរបសំរួលជាមួយផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ជំរុញការអនុវត្តន៍ច្បាប់ និងអនុសញ្ញាដែលទាក់ទង និងការហាមប្រាមប្រើប្រាស់មីនប្រឆាំងមនុស្សគ្រប់ប្រភេទជាដើម ។

៤. រាជរដ្ឋាភិបាល ផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សាភិបាលក្នុងការកែលំអរចនាសម្ព័ន្ធ នៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ( CMAC ) សំដៅធានាឲ្យបានក្នុងការបំពេញភារកិច្ចដោះស្រាយបញ្ហាមីនគ្រប់ប្រភេទ ដែលប្រកបដោយតម្លាភាព និងភាពអន្តរជាតិ ។

៥. ដើម្បីឲ្យមានអភិបាលកិច្ចល្អ រាជរដ្ឋាភិបាលស្វាគមន៍ចំពោះការចូលរួមរបស់តំណាងសហគមន៍អន្តរជាតិម្នាក់រូបឲ្យមកបំពេញតួនាទីជាសហនាយកប្រតិបត្តិ នៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ( CMAC ) ក្នុងមួយរយៈពេល ។ ក្នុងករណីដែលពុំមានការព្រមព្រៀងពីសហគមន៍អន្តរជាតិទាំងមូល ចំពោះការតែងតាំងសហនាយកប្រតិបត្តិនេះ រាជរដ្ឋាភិបាល ស្នើឲ្យអ្នកតំណាងសហគមន៍អន្តរជាតិដែលជាម្ចាស់ជំនួយ ធ្វើជាអ្នកផ្តល់មតិយោបល់ផ្នែកបច្ចេកទេសដល់ក្រុមប្រឹក្សាភិបាល និងតំណាងរបស់មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ឬតាមរូបមន្តណាមួយដែលមានការព្រមព្រៀងរវាងរាជរដ្ឋាភិបាល និងសហគមន៍អន្តរជាតិ ។

៦. រាជរដ្ឋាភិបាល នឹងខិតខំស្វែងរកប្រភពធនធានថ្នាក់ជាតិ ដើម្បីឧបត្ថម្ភគាំទ្រការដោះមីនឲ្យសមឋានៈជាម្ចាស់ប្រទេស ដែលរងគ្រោះដោយគ្រាប់មីន ។

៧. រាជរដ្ឋាភិបាល សូមសំដែងការដឹងគុណចំពោះសហគមន៍អន្តរជាតិ ដែលបានផ្តល់ជំនួយជាទៀងទាត់ និងជាបន្តបន្ទាប់ ដល់កិច្ចប្រតិបត្តិការដោះមីននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជាមូលដ្ឋាននៃការអភិវឌ្ឍន៍ជាតិ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៩

## ៥- សារាចរ

### សារាចរលេខ ០៥ សរ

### ស្តីអំពី អនាម័យស្បៀង និង អាហារូបត្ថម្ភ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

***

រាជរដ្ឋាភិបាលកម្ពុជា បានកំណត់ក្នុងកម្មវិធីនយោបាយស្តីពីការកាត់បន្ថយភាពក្រីក្រ ពង្រឹងការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងបង្កើនសុខុមាលភាពរបស់ប្រជាពលរដ្ឋ ជាពិសេសទប់ទល់នឹង

ការអត់ឃ្លាន ការខ្វះអាហារូបត្ថម្ភ និងភាពអសន្តិសុខស្បៀង ដែលកត្តាទាំងពីរនេះ គឺជាសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជា និង ជាការចាំបាច់ខាងផ្នែកសេដ្ឋកិច្ចសង្គម ថែមទៀតផង ។

ក្នុងឆន្ទៈដ៏មុះមុត ដើម្បីអភិវឌ្ឍន៍ប្រទេសជាតិអោយមានល្បឿនទៅមុខយ៉ាងឆាប់រហ័ស រាជរដ្ឋាភិបាល បានបង្កើតក្រសួង និងស្ថាប័នមួយចំនួនអោយទទួលបន្ទុកការងារស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ និងការងារអាហារូបត្ថម្ភកំរិតជាតិ និង ខេត្ត-ក្រុង ។ ការងារតាមដាននូវការអនុវត្តន៍ពើតរោងកសិកម្ម ពើតរោង ប្រើប្រាស់ធនធានទឹក និងពើតរោងអភិវឌ្ឍន៍ជនបទ ជាយន្តការពន្លឺះ ដែលនាំមកនូវប្រសិទ្ធភាពខ្ពស់ក្នុងការកាត់បន្ថយកង្វះអាហារូបត្ថម្ភ និងការកាត់បន្ថយអសន្តិសុខស្បៀងជា ពិសេសលើស្ត្រី និងកុមារ ។

ដើម្បីធានាអោយនូវ សន្តិសុខស្បៀងជូនដល់ប្រជាពលរដ្ឋ ស្របតាមនិយមន័យ ដែលបានចែងថា : " ជានិច្ចកាល កាលណា ប្រជារាស្ត្រគ្រប់រូប គ្រប់ពេល បានទទួលសន្តិសុខស្បៀង និងអាហារូបត្ថម្ភដោយគ្រប់គ្រាន់ និងដោយសុវត្ថិភាព ហើយនិងបានទទួលសេចក្តីត្រូវការខាងម្ហូបអាហារ និងជំរើសម្ហូបអោយការសំរាប់ជីវភាពរស់នៅដ៏សកម្ម និង សុខដុម រមនារបស់គេ " រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការ ដោយប្រគល់ភារកិច្ចជូនក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ដែលមានតួនាទីជាអ្នកសំរបសំរួលជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់ខេត្ត-ក្រុង អោយទទួលអនុវត្តអនុសាសន៍នានាដែលមានចែងក្នុងសេចក្តីសំរេចចិត្តនៃអង្គសិក្ខាសាលាជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនាថ្ងៃទី២០-២១ ខែមេសា ឆ្នាំ១៩៩៩ ដូចខាងក្រោម :

## I- អនុសាសន៍សំរាប់ថ្នាក់ជាតិ

១-រាជរដ្ឋាភិបាលប្រគល់សិទ្ធិពេញលេញជូនអភិបាលខេត្ត-ក្រុង ដើម្បីដោះស្រាយបញ្ហាទំនាស់ដីធ្លី ដោយផ្អែកលើមូលដ្ឋានច្បាប់ ហើយទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល ព្រមទាំងរាយការណ៍អំពីលទ្ធផល និងវិធានការជូនរាជរដ្ឋាភិបាលរៀងរាល់ បីខែម្តង ចាប់ផ្តើមពីថ្ងៃដែល រាជរដ្ឋាភិបាលកំណត់ ។

២-រាជរដ្ឋាភិបាលចេញអនុក្រឹត្យ ឬសេចក្តីសំរេច លុបចោលនូវគ្រប់សិទ្ធិកាន់កាប់ដីធ្លីណាដែលបានពីការ រំលោភ បំពាន និងទិញលក់ដោយខុសច្បាប់ ។

៣-ផ្តន្ទាទោសចំពោះមន្ត្រីខិលខូចដែលចេញប័ណ្ណកាន់កាប់ដីធ្លីដោយបំពាន ។

៤-រាជរដ្ឋាភិបាលត្រូវកំណត់អោយបានច្បាស់នូវព្រំដែន និងប្រភេទដីដែលត្រូវប្រើប្រាស់សំរាប់ កសិកម្ម ផលិតផលព្រៃឈើ ព្រៃបំរុងទុក និងតំបន់ការពារធម្មជាតិ ។ល។

៥-សំរួលដល់ការអនុវត្តន៍វិនិយោគដីសម្បទាន ហើយត្រួតពិនិត្យលើដំណើរការអនុវត្តន៍របស់អ្នកវិនិយោគ និងមានវិធានការលុបចោល បើក្រុមហ៊ុនណាមិនបានអនុវត្តត្រឹមត្រូវ តាមកិច្ចសន្យា ។

៦-ពង្រីកផ្ទៃដីកសិកម្មតាមរយៈតាំងទីលំនៅថ្មីដោយស្ម័គ្រចិត្តនៅ តំបន់ដីដែលមានឧប្បនិស្ស័យកសិកម្ម ។

៧-ផ្តល់ដីធ្លីនិងសិទ្ធិកាន់កាប់ដីធ្លី ដើម្បីធានាអោយមានកម្មសិទ្ធដល់គ្រួសារក្រីក្រនិងគ្រួសារគ្មានដីធ្លី ។

៨-អនុម័តយកផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជា ( CNIP ) ជាផ្នែកមួយនៃគំរោងវិនិយោគសាធារណៈ ( PIP ) ក្នុងគោលបំណងយ៉ាងដាច់អោយបានសំរេចក្នុងរយៈពេល ១០ ឆ្នាំ ទៅមុខនូវទិសដៅ :

- កាត់បន្ថយពាក់កណ្តាលកំរិតខ្វះខាតអាហារូបត្ថម្ភ ប្រូតេអ៊ីន ថាមពល ( PEM) ដែលបច្ចុប្បន្នមាន កំរិត ៥២% អោយមកនៅត្រឹម ២៦% ចំពោះកុមារដែលមានអាយុក្រោម ៥ ឆ្នាំ ។
- លុបបំបាត់បញ្ហាកង្វះជាតិអ៊ីយ៉ូត ( LDD ) និងជីវជាតិអា ( VAD ) ។
- កាត់បន្ថយចំនួនពាក់កណ្តាលនៃជំងឺខ្វះឈាមក្រហមរបស់ស្ត្រីមានផ្ទៃពោះនិងកុមារ ដែលមានអាយុក្រោម ៥ ឆ្នាំ ពីកំរិតបច្ចុប្បន្ន ៧០% មកនៅត្រឹម ៣៥ % ។
- កាត់បន្ថយអត្រានៃការកើតមិនគ្រប់ទំងន់របស់ទារកនៅពេលសំរាល ( ស្រាលជាង ២៥០០ ក្រាម ) ពី ២០% អោយមកនៅតិចជាង ១០ % ។
- កាត់បន្ថយពី ២៥% មកនៅក្រោម ១០% ចំពោះបញ្ហាសន្ទស្សន៍សុខភាពរាងកាយរបស់ស្ត្រី ( BMI ) ដែលស្ថិតក្នុងវ័យបន្តពូជ ក្នុងជំពូកដែលបានវាស់វែងទៅឃើញតួលេខតិចជាង ១៨.៥ គក្រ/ម$^{២}$ ។

៩-ដាក់អោយមានការផ្សាយពត៌មានតាមវិទ្យុ ទូរទស្សន៍ ដោយមិនបាច់បង់ថ្លៃ ផ្តល់ជូននូវសេវាសាធារណៈប្រចាំខែ ស្តីពីការអប់រំខាងអាហារូបត្ថម្ភ សុខភាព ការចាក់ថ្នាំបង្ការ ការបំបៅដោះកូន ការអនុវត្តន៍ ក្នុងការផ្តល់ចំណីអាហារដល់កូន និងអនាម័យខ្លួនប្រាណ ( ទឹកស្អាតនិងអនាម័យទូទៅ ) ។

១០-គាំទ្រលទ្ធភាពផ្តល់ការអប់រំប្រកបដោយគុណភាពដល់កុមារ ជាពិសេសកុមារី និងបញ្ចូលក្នុងកម្មវិធី សិក្សាអំពី សុខភាព អនាម័យទូទៅ និង អាហារូបត្ថម្ភ ។

១១-ផ្តល់អាទិភាពលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ ។

១២-បង្កើតគណៈកម្មការគ្រប់គ្រងប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភដំណើរការនិងអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានផ្នែកអាហារូបត្ថម្ភជាតិដែលពាក់ព័ន្ធនឹងសុខភាព ក្នុងការគាំទ្រយុទ្ធសាស្ត្រមូលដ្ឋាន កំរិតសហគមន៍ និងកំរិតជាតិ ហើយធ្វើការពិនិត្យតាមដាន និងវាយតំលៃលើការវិវឌ្ឍន៍នៃការថយចុះកង្វះអាហារូបត្ថម្ភ លើស្ត្រីនិងកុមារ ។

១៣-បញ្ចូលនូវតម្រូវការថវិកាស្តីពីអន្តរាគមន៍ដែលពាក់ព័ន្ធនឹងអាហារូបត្ថម្ភ ក្នុងថវិកាជាតិ និងមាននយោបាយសមស្រប សំរាប់ ផែនការ អភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ៥ ឆ្នាំ របស់រាជរដ្ឋាភិបាល ។

១៤-បង្កើនសមត្ថភាពនិងជំនាញនៅតាមស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងផែនការ ក្រសួងសុខាភិបាល និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីលើកឡើងពីបញ្ហាអាហារូបត្ថម្ភ តាមរយៈកម្មវិធីផ្សេងៗ មានការបណ្តុះបណ្តាល និងការសិក្សាស្រាវជ្រាវលើការវិភាគលើភាពងាយរងគ្រោះ និងកំណត់ភូមិសាស្ត្រ ។

១៥-ជំរុញការផលិតអំបិលដែលមានជាតិអ៊ីយ៉ូតទូទាំងប្រទេស អោយបានក្នុងដំណាច់ឆ្នាំ ១៩៩៩ និងរៀបចំបទដ្ឋានអោយបានដាច់ពីគ្នា ក្នុងការលក់ និង ការនាំចូលអំបិលដែលមានជាតិអ៊ីយ៉ូតសំរាប់មនុស្ស និងសត្វបរិភោគ ក្នុងដំណាច់ឆ្នាំ ២០០០ ។

១៦-អនុម័តនិងដាក់អោយប្រើប្រាស់នូវបទដ្ឋានជាតិ ចំពោះប្រភេទគុណភាពចំណីអាហារ ពិសេសទឹកដោះសត្វសំរាប់កុមារ នៅលើទីផ្សារ ។

១៧-ត្រូវកំណត់តួនាទីនៃជំនួយស្បៀងអាហារនៅក្នុងផែនការ ៥ឆ្នាំ ( ២០០០-២០០៥ ) របស់រាជរដ្ឋាភិបាល ។

១៨-ជំរុញ និងអនុវត្តប្រភេទផលិតកម្មកសិកម្មចំរុះ ជាពិសេសតំបន់ដែលធ្វើស្រែមិនបានត្រូវដាំដំណាំផ្សេងវិញ ។

១៩-បង្កើត និងពង្រឹងប្រព័ន្ធទីផ្សារកសិកម្ម អោយបានខ្លាំងក្លា ដើម្បីលក់ជូនក្នុងតំបែតោកទៅតំបន់អសន្តិសុខស្បៀង ។

២០-ជំរុញលើកកំពស់ បង្កើនសកម្មភាពសេដ្ឋកិច្ចជនបទចំរុះ បង្កើនការងារតាមរយៈការកែច្នៃផលិតផលកសិកម្មក្នុងស្រុក និង បង្កើនការបើកទូលាយឥណទានជនបទ ។

២១-លើកកំពស់ប្រពលវប្បកម្មកសិកម្ម និងពង្រីកកែលំអគេហកម្មកសិកម្មសំរាប់ដំណាំផ្សេងៗ ក៏ដូចជាការចិញ្ចឹមសត្វពាហនៈ និងត្រី ។

២២-ជំរុញការវិនិយោគសាធារណៈលើប្រព័ន្ធធារាសាស្ត្រ និងសិក្សាស្រាវជ្រាវលើហេដ្ឋារចនាសម្ព័ន្ធកសិកម្ម រួមទាំងការលើកទឹកចិត្តដល់ការវិនិយោគឯកជនលើប្រព័ន្ធធារាសាស្ត្រខ្នាតតូចនិងមធ្យម។

២៣-លើកទឹកចិត្តដល់ការត្រួតពិនិត្យគុណភាពកសិផលនាំចូល ដោយមិនអោយប៉ះពាល់ដល់បរិស្ថាន និងសេដ្ឋកិច្ចក្នុងខណៈដែលយើងកំពុងបន្តការនាំចេញ ។

២៤-ការងារផលិតកម្មស្បៀងគឺជាភារកិច្ចទទួលខុសត្រូវរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរដែនដីដោយមានការគាំទ្រពី សហគមន៍អន្តរជាតិ ម្ចាស់ជំនួយទ្វេភាគី ដូចជា CIAP, FAO,WFP, UNICEF, UNDP,World Bank, Asian Development Bank ។ ល។

## II- អនុសាសន៍សំរាប់ថ្នាក់សហគមន៍

១-ផ្តល់សិទ្ធដល់ថ្នាក់ខេត្តក្នុងការបើកគំរោងផែនការចាត់ចែងដីធ្លី លើការផ្តល់ប័ណ្ណកាន់កាប់ដីធ្លី និង លើការរៀបចំតំបន់អភិវឌ្ឍន៍លើដីទំនេរ និងជាពិសេសលើដីតាមព្រំដែន ។

២-អាជ្ញាធរខេត្តគួររៀបចំគោលនយោបាយចំពោះគ្រួសារដែលគ្មានដីធ្លី ដោយអនុញ្ញាតឲ្យគេមានលទ្ធភាពទទួល ដីធ្លីតាមដំណោះស្រាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ។

៣-បង្កើនការយល់ដឹងដល់មហាជនអំពីបញ្ហាអាហារូបត្ថម្ភ (ឧ.ស្បៀងគឺមិនមែនមានតែអង្ករ បាយមួយមុខនោះទេ ) ។

៤-ផ្តល់បរិក្ខារដល់មណ្ឌលសុខភាពដើម្បីលើកកំពស់ ពិនិត្យតាមដានលើការលូតលាស់របស់កុមារ និងការផ្តល់ការថែទាំសុខភាពដល់ស្ត្រីដែលមានផ្ទៃពោះ ។

៥-ជំរុញ និងលើកស្ទួយកម្មវិធីចាក់ថ្នាំបង្ការ ទោះបីជា នៅភូមិដាច់ស្រយាលយ៉ាងណាក៏ដោយ ។

៦-ផ្តល់បច្ចេកទេសវិទ្យាដើម្បីសំរួលបន្ទុកការងារដល់ស្ត្រី ។

៧-លើកទឹកចិត្ត និងទាក់ទាញឲ្យមានវិនិយោគទុនឯកជន ដោយមានដំណើរការនៅថ្នាក់ខេត្ត និងស្រុក ដើម្បីបង្កើនការងារនៅមូលដ្ឋាន ។

៨-ជំរុញស្ថាប័នហិរញ្ញវត្ថុជនបទក្នុងការពង្រីក ឥណទានជនបទ សេវាសន្សំប្រាក់ ដោយជំនួសម្ចាស់លុយឯកជន ដែលយកការប្រាក់ខ្ពស់ ។

៩-ត្រូវកំណត់អោយច្បាស់ថា ឥណទានមានគ្រប់គ្រាន់សំរាប់តំរូវការឥណទានតាមរដូវកាល ។

១០-ជំរុញអោយមានការយល់ដឹងអំពីបរិស្ថាន និងវប្បធម៌ តាមសហគមន៍ ។

១១-ពង្រឹង និងជំរុញដំណើរការរៀបចំគណៈកម្មាធិការអភិវឌ្ឍន៍ជនបទ ខេត្ត-ក្រុង ឃុំ និង ភូមិ ឲ្យអនុវត្តភារកិច្ចឲ្យបានសកម្ម ។

១២-ជំរុញ និងគាំទ្រលើបញ្ហាអាហារូបត្ថម្ភនៅតាម ថ្នាក់ខេត្ត-ក្រុង និងថ្នាក់បន្ទាប់ៗក្នុងស្ថាប័នជាតិ ។

១៣-ជួយក្នុងការស្វែងយល់ រកក្រុមជនងាយរងគ្រោះ នៅតាមថ្នាក់ឃុំ ។

១៤-ផ្តល់ការគាំទ្រដល់ការរៀបចំតាក់តែងថ្នាក់ឃុំ ភូមិ និងការរៀបចំឲ្យមានគណៈកម្មការអភិវឌ្ឍន៍ថ្នាក់ឃុំ ភូមិ ។

១៥-ផ្តល់ និងធ្វើឲ្យប្រសើរឡើងនូវផ្លូវថ្នល់ទៅកាន់ ទីផ្សារ មណ្ឌលសុខភាព និងសេវាសិក្សាធិការ ឲ្យបានគ្រប់រដូវកាល ។

១៦-ធ្វើឲ្យប្រសើរឡើងនូវលទ្ធភាពប្រើប្រាស់ទឹកស្អាត និងអនាម័យ ។

១៧-ធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធទូរគមនាគមន៍ និងទាក់ទាញអ្នកវិនិយោគទុនឯកជន ឲ្យផ្តល់សេវាប្រតិបត្តិ និងថែទាំ (ឧ.ថ្លៃឈ្នួលការប្រើប្រាស់ប្រព័ន្ធ ទូរគមនាគមន៍ ) ។

១៨-ជួយផ្តល់នូវចំណេះដឹង និងចំណេះធ្វើ ក្នុងការបង្កបង្កើនផលដំណាំកសិកម្មចំរុះ ( បន្លែ ឈើហូបផ្លែ បសុសត្វ និងត្រី ) និងរកប្រាក់ចំណូលបន្ថែមក្រៅពីការងារកសិកម្ម ។

១៩-ជួយក្នុងការផ្តល់លទ្ធភាពរកស្បៀង និងប្រាក់ ចំណូលតាមរដូវកាល តាមរយៈការណែនាំ អោយដាំដំណាំចំរុះ និងការបង្កើនសមត្ថភាពក៏ដូចជាតាមរយៈធនាគារស្រូវ និង តាមរយៈស្តុកដែលមាន។

២០-ណែនាំអប់រំសហគមន៍ឲ្យចេះប្រើប្រាស់ធនធានធម្មជាតិ ឲ្យមាននិរន្តរភាព និងស្របតាមបទបញ្ញត្តិច្បាប់ ដែលពាក់ព័ន្ធ ។

២១-លើកស្ទួយ និងបង្កើនគុណភាពផលិតផលក្នុងស្រុក រួមទាំងការកែច្នៃចំណីអាហារ ដើម្បីបំពេញតម្រូវការទីផ្សារជំនួសផលិតផល នាំចូល ហើយឈានដល់ការនាំចេញ ។

២២-ផ្តល់នូវសេវាកម្មពត៌មានពីតំលៃរបស់ ផលិតផលឲ្យបានទៀងទាត់ទៅអ្នកផលិត ។

២៣-ការទាក់ទាញមតិគាំទ្រពីទីភ្នាក់ងារអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលក្នុងការគាំទ្រសកម្មភាពជាមូលដ្ឋាននូវសហគមន៍ដែលនាំអោយមានភាពល្អប្រសើរឡើង នូវស្ថានភាពអាហារូបត្ថម្ភសំរាប់កុមារ និងស្ត្រី ។

## III- អនុសាសន៍សំរាប់ថ្នាក់គ្រួសារ

១-លើកកំពស់ការអនុវត្តន៍នូវការបំបៅដោះម្តាយ និងការផ្តល់ចំណីអាហារបន្ថែម ជារួមមាន ការបំបៅទឹកដោះម្តាយសុទ្ធ ពេលកុមារមានអាយុពី ៤-៦ ខែ ការផ្តល់ទឹកដោះដំបូង ការអនុវត្តន៍និងផ្តល់ចំណីអាហារអោយបានញឹកញាប់ដែលបង្កើននូវគុណភាពជីវជាតិក្នុងចំណីអាហារ ។

២-ជំរុញការផ្តល់អាហារផ្សេងៗ ច្រើនមុខនិងកាត់បន្ថយនូវការខ្វះមីក្រូសារជាតិ ជាពិសេសតាមរយៈការដាំដំណាំតាមគ្រួសារ និងកែលំអនូវទំលាប់តមចំណីអាហារសំរាប់កុមារ ស្ត្រីមានផ្ទៃពោះនិងស្ត្រីកំពុងបំបៅដោះកូន ។

៣-លើកតំកើងការប្រើប្រាស់សេវាសុខភាពសំរាប់ការថែទាំមាតានិងទារកជារួមមានៈ ការថែរក្សាស្ត្រីមានផ្ទៃពោះ ការចាក់ថ្នាំបង្ការ ការផ្តល់ថ្នាំគ្រាប់វីតាមីនអា ជាតិដែក និងអាស៊ីតហ្វូលិក ។

៤-ជំរុញការអនុវត្តន៍អនាម័យដូចជាការសាងសង់បង្គន់អនាម័យ និងការប្រើប្រាស់បង្គន់អនាម័យ លាងដៃនឹងសាប៊ូមុនពេលបរិភោគអាហារ និងដាំទឹកសំរាប់អោយកុមារផឹក ។

៥-រៀបចំនិងពង្រឹង និងអនុវត្តគោលការណ៍ដែលផ្តល់អាទិភាពដល់ការធ្វើអោយស្ថានភាពសេដ្ឋកិច្ចសង្គមរបស់គ្រួសារ មានភាពល្អប្រសើរឡើងជារួមមាន ៖ សិទ្ធិដីធ្លី កម្មវិធីអក្ខរកម្ម ផ្តល់ជំនាញខាងការផ្សព្វផ្សាយ ( ឧ. កសិកម្ម, អប់រំ ។ល។ ) និងការបង្កើនប្រាក់ចំណូលតាមរយៈឥណទានខ្នាតតូច ។

៦-លើកកំពស់ការប្រើប្រាស់អោយបានល្អនូវធនធានដែលអាចរកបាន រួមមាន ៖ ស្បៀងផ្សេងៗ ការប្រើប្រាស់សេវាសុខាភិបាលនានា ផែនការគ្រួសារ លុបបំបាត់សកម្មភាពមិនស្របច្បាប់ដូចជាល្បែងស៊ីសង និងភាពស្រវឹង ។

៧-លើកស្ទួយដល់ការថែរក្សាព្យាបាលសុខភាពកុមារនិងទារកនៅក្នុងគ្រួសារដោយអាណាព្យាបាល និងអ្នកដែលបានទទួលការបណ្តុះបណ្តាលផ្នែកសុខភាព ។

៨-ជំរុញនិងលើកទឹកចិត្តអោយមានសួនបន្លែ ជាពិសេសគ្រួសារសំរាប់ប្រុងប្រយ័ត្ន និងលក់ផ្សារ ។

៩-ផ្តល់លទ្ធភាព និងលើកទឹកចិត្តដល់ការធ្វើផែនការគ្រួសារ ( ពន្យារកំណើត ) " គ្រួសាររីករាយ " កែទស្សនៈពី " កូនច្រើនក្រ " មក " កូនតិច " សប្បាយរុងរឿង និងការថែទាំសុខភាពផ្លូវភេទ ។

ទទួលបានសារាចរនេះ រាជរដ្ឋាភិបាលសង្ឃឹមជឿជាក់លើស្មារតីទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ន និងអាជ្ញាធរ ដែនដីគ្រប់ខេត្ត-ក្រុង ក្នុងការចាត់ចែងផ្សព្វផ្សាយ និង អនុវត្តអោយទទួលបាននូវប្រសិទ្ធភាពខ្ពស់ ហើយសូមរាយការណ៍អំពីលទ្ធភាពផលដែលសំរេចបាន តាមឥណាក់កាលនិមួយៗ មកទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានយន្តការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទជាសេនាធិការប្រមូលនូវស្ថិតិទិន្នន័យលទ្ធផល ចងក្រងឯកសារជាមូលដ្ឋានសំរាប់វិភាគជូននាយករដ្ឋមន្ត្រី ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

រាជធានីភ្នំពេញ,ថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩

# សារាចរណែនាំ

## សារាចរណែនាំលេខ ០៧ សរណន

## ស្តីពីការចាត់តាំងរៀបចំឆិទាមហោស្រពអន្តរ

## ឆ្នាំ ១៩៩៩-២០០០

***

ឆ្លងកាត់សង្គ្រាមរ៉ាំរ៉ៃជាច្រើនឆ្នាំ ព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលគ្រោះមហន្តរាយយ៉ាងធ្ងន់ធ្ងរទាំងសំភារៈជាឆ្អឹងខ្នងរបស់សង្គម និង ទាំងបញ្ញាញាណរបស់មនុស្សជាតិ ។ ផលវិបាកនៃសង្គ្រាមបានបន្សល់ទុកនូវសោកនាដកម្មយ៉ាងឈឺចាប់ ទាំងក្នុងជាតិទាំងនៅលើឆាកអន្តរជាតិ ។

បណ្តាអត្តសញ្ញាណជាតិ ដែលក្នុងនោះមានវិស័យវប្បធម៌ អរិយធម៌ខ្មែរយើង ដែលធ្លាប់តែល្បីល្បាញ រុងរឿង ទទួលបានកិត្តិយស និង ថ្លៃថ្នូរពីអតីតកាល ក៏ត្រូវបានធ្លាក់ចុះយ៉ាងខ្លាំងគួរអោយព្រួយបារម្ភ ។

ប៉ុន្តែចាប់ពីក្រោយថ្ងៃជ័យជំនះ ៧មករា ១៩៧៩ មក យើងបានរួមគ្នាជួសជុលស្តារ និង កសាង នូវអ្វីដែលបាក់បែកទ្រុឌទ្រោម បាត់បង់ និង កសាងថ្មី អោយកើតមានឡើងវិញជាបណ្តើរៗ រហូតមានការប្រែមុខមាត់ថ្មី ដូចសព្វថ្ងៃនេះ ។

យោងតាមការចាំបាច់ នៃកាលានុវត្តភាព បើកឆ្នាំសន្តិភាព ទេសចរណ៍ ឆ្លងដំណាក់សតវត្សទី២០ ឈានចូលដល់សហស្សវត្សថ្មី នៃសន្តិភាព និង ការអភិវឌ្ឍន៍ ។

រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានគំរោងរៀបចំទិវាមហោស្រពអង្គរ ឆ្នាំ ១៩៩៩-២០០០ ដែលនឹង ប្រព្រឹត្តនៅរយៈពេល ០៣ថ្ងៃ ចាប់ពីថ្ងៃទី៣០-៣១ ខែធ្នូ ឆ្នាំ១៩៩៩ ដែលជាថ្ងៃបិទសតវត្សទី២០ និងដល់ថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០០ ជាថ្ងៃចាប់ផ្តើមបើកសតវត្សទី២១ នៅមុខប្រាសាទអង្គរវត្ត ក្នុងគោលបំណងបង្ហាញ ជូនមតិជាតិ និង អន្តរជាតិនូវ :

ក-អត្តសញ្ញាណជាតិខ្មែរ តំណវង្សពីសម័យអង្គរ

ខ-វប្បធម៌ អរិយធម៌ ដ៏រុងរឿងនាសម័យអង្គរផ្សារភ្ជាប់ទៅ នឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលបច្ចុប្បន្ន ក្នុងជំហរលើកកំពស់ :

- ការពង្រឹងសន្តិភាព
- ផ្សះផ្សាជាតិ និង បង្រួបបង្រួមជាតិ
- សាមគ្គីធម៌ជាតិ និង អន្តរជាតិ
- ការស្តារ ជីវភាព កិត្តិយស និង សីលធម៌រស់នៅថ្ងៃថ្មីរបស់ប្រជាពលរដ្ឋខ្មែរ
- តាមរូបភាពនិងខ្លឹមសារនៃទស្សនីយភាព ប្រែក្លាយទិវាមហោស្រពនេះអោយទៅជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រពិភពលោកមួយ សំដៅបំបាត់រាល់ការបង្កាច់បង្ខូចកេរ្តិ៍ឈ្មោះ ខ្មែរពីសំណាក់បរទេសក្នុងរយៈពេលកន្លងមក ដោយប្តេជ្ញាទទួលខុសត្រូវវាសនាខ្លួនឯងនៅថ្ងៃអនាគត ។

ដើម្បីធ្វើអោយទិវាមហោស្រពអង្គរ ឆ្នាំ ១៩៩៩-២០០០ ប្រព្រឹត្តទៅឆ្លើយតបបានសមស្រប តាមគោលបំណង និង សំណូមពរខាងលើ រាជរដ្ឋាភិបាល សូមដាក់ចេញសារាចរណែនាំដូចតទៅនេះ :

**+ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

-ត្រូវរៀបចំគំរោងប្រធានបទ និង ខ្លឹមសារ រូបភាព ស្តីពីទិវាមហោស្រពអង្គរឆ្នាំ ១៩៩៩-២០០០ នៅមុខទីលានអង្គរវត្ត និង តាមប្រាសាទបុរាណនានាដើម្បីបង្ហាញដល់ភ្ញៀវជាតិ អន្តរជាតិ ។

-រៀបចំធ្វើជាសៀវភៅបត់ ស្ដីពីរូបភាពប្រពៃណីជាតិសំខាន់ៗ រូបភាពបណ្ដាប្រាសាទបុរាណ របស់ណាក់ពីរបុរសជាតិ និង ស្នាដៃ វិចិត្រសិល្បករចាស់ៗ ។

-រៀបចំទស្សនីយភាពសិល្បៈ ល្ខោននិយាយ ក្រុមសិល្បៈបុរាណប្រពៃណី ក្រុមរបាំប្រពៃណី ក្រុមយីកេ ណាំងស្បែក ។ល។

-ចាត់តាំងពិធីប្រឡងជ្រើសរើសអត្ថបទកំណាព្យ ស្ដីពីអត្ថន័យទិវាមហោស្រពអង្គរ ឆ្នាំ ១៩៩៩-២០០០ ភ្ជាប់ទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល និង សិល្បៈបុរាណមានភ្លេងខ្មែរប្រពៃណី អាយ៉ៃ ឆ្លើយឆ្លង ចាប៉ី...។ល។ សំលៀកបំពាក់បុរាណខ្មែរ ក្បាច់គុណខ្មែរ និងល្បែងប្រជាប្រិយខ្មែរ ដើម្បីបង្ហាញយុវជនជំនាន់ក្រោយបានយល់ច្បាស់ និងបន្តថែរក្សាអោយបានគង់វង្ស។

+ក្រសួងទេសចរណ៍ :

-បំផុស អំពាវនាវមហាជន ជាអ្នកទេសចរណ៍ជាតិ អន្តរជាតិ ចូលរួមអោយបានច្រើនកុះករ ។

-ធ្វើការណែនាំដល់មន្ទីរទេសចរណ៍ ខេត្ត-ក្រុង ក្រុមហ៊ុនទេសចរណ៍ឯកជន អោយធ្វើការផ្សព្វផ្សាយ អំពីអត្ថន័យ ខ្លឹមសារនៃទិវាមហោស្រពអង្គរ ឆ្នាំ ១៩៩៩-២០០០ អោយបានជ្រួតជ្រាបទូលំទូលាយ និងបំផុស អោយប្រជាពលរដ្ឋផលិតនូវវត្ថុសិល្បៈ ពាក់ព័ន្ធនឹងវប្បធម៌ អរិយធម៌ អង្គរ ជាពិសេស ប្រជាពលរដ្ឋនៅខេត្តសៀមរាបរៀបចំចាត់តាំងពិពណ៌សិប្បកម្ម ដើម្បីលក់យកកំរៃជាប្រយោជន៍ផ្ទាល់ខ្លួន ។

-ធ្វើប៉ាណូ អាហ្វីស និង សៀវភៅរូបភាព ស្ដីពីការវិវឌ្ឍន៍ នៃវិស័យទេសចរណ៍បច្ចុប្បន្ន និងគំពោងផែនការថ្មីទៅអនាគត ។

-ជួយទំនាក់ទំនងត្រៀមបំរុងសណ្ឋាគារ និង ជួយសំរួលមធ្យោបាយដឹកនាំភ្ញៀវទេសចរណ៍ជាតិ និង អន្តរជាតិ ដែលត្រូវទៅចូលរួមទិវាមហោស្រពអង្គរនៅភ្នំពេញក៏ដូចនៅសៀមរាប ។

-ធ្វើការផ្សព្វផ្សាយទាក់ទាញភ្ញៀវទេសចរណ៍ គ្រប់រូបភាពស្ដីពីព្រឹត្តិការណ៍ ទិវាមហោស្រពអង្គរលើឆាកជាតិ អន្តរជាតិអោយបានទូលំទូលាយ ។

+ អាជ្ញាធរអប្សរា :

-ត្រៀមលក្ខណៈ និង រៀបចំទីលានមុខប្រាសាទអង្គរវត្ត និង ប្រាសាទនានា អោយបានស្អាតល្អ ដើម្បីប្រារព្ធពិធីទិវាមហោស្រពអង្គរ ឆ្នាំ ១៩៩៩-២០០០ និង ខិតខំបើកទីតាំងប្រាសាទបុរាណ

មួយចំនួនទៀត ដូចជាទីលាន ជល់ដំរី ស្រះស្រង់ជាដើម ដើម្បីផ្តល់លទ្ធភាពជូនភ្ញៀវទេសចរណ៍ចូលទស្សនា ស្វែងយល់ និងធ្វើនិទស្សន៍ អំពីផ្កាំ សន្តិភាព ទេសចរណ៍ តាំងភ្លើងពណ៌ផ្សេងៗ ដុតចន្លុះភ្លឺព្រោងព្រាតតាមប្រាសាទនានា ។ល ។

-រៀបចំកែលំអបរិវេណជុំវិញប្រាសាទអង្គរវត្ត អោយបានស្អាតដោយព្រួសត្រាយព្រៃស៊ុបទ្រុបដាំស្មៅ អោយមានរបៀបរៀបរយ និងធ្វើអនាម័យសំអាត ធានាបានបរិស្ថានជុំវិញ ។

**+ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និង អាកាសចរត្ស៊ូមិន្ទកម្ពុជា :**

-ត្រៀមលក្ខណៈរៀបចំទីតាំងព្រលានយន្តហោះសៀមរាប អោយបានស្អាតល្អ ដោយតុបតែងកែលំអ បដាពាក្យស្លោកទង់ជាតិ ទង់ផ្កាលោ និងបង្កលក្ខណៈងាយស្រួលសំរាប់ភ្ញៀវចេញ ចូលព្រលាន ព្រមទាំងត្រៀមយន្តហោះសំរាប់ភ្ញៀវទេសចរណ៍ ដែលនឹងត្រូវចូលរួមដឹកជញ្ជូនទាន់ពេលវេលា ។

**+ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ :**

-ជូនដំណឹងនឹងផ្តល់ពត៌មានដល់បណ្តាស្ថានទូត ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងស្ថានទូតកម្ពុជានៅឯបរទេស បណ្តាអង្គការអន្តរជាតិ អំពីខ្លឹមសារ អត្ថន័យ កាលបរិច្ឆេទទីតាំង និង លទ្ធភាពរបស់យើង នៃទិវាមហោស្រពអង្គរ ឆ្នាំ ១៩៩៩-២០០០ ។

-អំពាវនាវអ្នកទេសចរណ៍ អន្តរជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិចូលរួមអោយបានច្រើនកុះករ ។

**+ ក្រសួងអប់រំយុវជន និងកីឡា និងក្រសួងធម្មការ និង សាសនា :**

-ត្រូវធ្វើការផ្សព្វផ្សាយ អប់រំដល់បុគ្គលិកសិក្សា លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត ព្រះសង្ឃអាចារ្យ គណៈកម្មការវត្ត ព្រមទាំងពុទ្ធបរិស័ទ ក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា អោយចូលរួមចំណែកលើកកំពស់ទិវាមហោស្រពអង្គរ ឆ្នាំ ១៩៩៩-២០០០ និង ផលិតស្នាដៃឧទ្ទិសទិវាប្រវត្តិសាស្ត្រនេះ តាមផ្នែកជំនាញរៀងៗខ្លួន ។

**+ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ខេត្តសៀមរាប និងបណ្តាខេត្ត-ក្រុង :**

-ត្រូវធ្វើការអប់រំដល់មន្ត្រីរាជការ នគរបាលជាតិ កងយោធពលខេមរភូមិន្ទ និង ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ អោយបានយល់ពីអត្ថន័យ ខ្លឹមសារ នៃទិវាមហោស្រពអង្គរ ឆ្នាំ ១៩៩៩-២០០០

និងចូលរួមបំរើអោយទិវាជាប្រវត្តិសាស្ត្រនេះ ប្រព្រឹត្តទៅប្រកបដោយ អនាម័យស្អាតល្អ សុវត្ថិភាព សប្បាយរីករាយ និង ស្ថិតក្នុងបរិយាកាសសាមគ្គីល្អប្រសើរ ។ ខេត្ត-ក្រុងដទៃ ក្រៅពី ខេត្តសៀមរាប អាចនឹងចាត់តាំងទិវាមហោស្រពអង្គរ ឆ្នាំ ១៩៩៩-២០០០ នៅក្នុងក្របខ័ណ្ឌ ខេត្ត-ក្រុង របស់ខ្លួន ដោយជ្រើសរើសយកទីតាំងមានប្រាសាទបូរាណ បូជនីយដ្ឋានណាមួយរបស់ខេត្ត-ក្រុង សំរាប់ប្រារព្ធពិធីតាមលទ្ធភាពជាក់ស្តែង ។

-ត្រូវធ្វើការណែនាំដល់អង្គភាព ក្រោមឱវាទ សហការការពារសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់សង្គមនៅទីតាំងប្រារព្ធពិធីនាទីលានប្រាសាទអង្គរវត្ត និង ទីតាំងផ្សេងៗ ទៀតដែលខេត្ត-ក្រុង នីមួយៗជ្រើសរើសជាទីលានចាត់តាំងប្រារព្ធពិធីអោយបានល្អ ។

**+ ក្រសួងពត៌មាន :**

-តាមដានស្រាវជ្រាវ និង ផ្សព្វផ្សាយតាមវិទ្យុ និង ទូរទស្សន៍ សារពត៌មាន ជាតិ ឯកជន នូវអត្ថន័យ ខ្លឹមសារ នៃទិវាមហោស្រពអង្គរ ឆ្នាំ ១៩៩៩-២០០០ អោយបានទូលំទូលាយ គ្រប់រូបភាព តាមទិសស្លោកអ្វីៗទាំងអស់ឆ្ពោះទៅឆ្នាំ ២០០០ ។

-ជ្រើសរើសប្រឡងសំដែងទស្សនីភាព សិល្បៈ បូរាណ សម័យ អាយ៉ៃឆ្លើយឆ្លង ចាប៉ី កំប្លែងខ្លីសំនួរ ចំលើយ ស្តីពីទិវាមហោស្រពអង្គរ សន្តិភាព ឆ្នាំ ២០០០ ។

**+ ក្រសួងសាធារណការ និងដឹកជញ្ជូន :**

-ត្រូវធ្វើការជួសជុលផ្លូវថ្នល់- ស្ពាន ពីភ្នំពេញទៅសៀមរាប អោយបានល្អទាន់ពេលវេលា

-ត្រៀមមធ្យោបាយដឹកជញ្ជូនភ្ញៀវជាតិ- អន្តរជាតិ តាមផ្លូវគោក និងផ្លូវទឹក អោយបានទាន់ពេលវេលា ។

**+ គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ អន្តរជាតិ :**

-ត្រៀមលក្ខណៈអញ្ជើញថ្នាក់ដឹកនាំ និង អ្នកមុខ អ្នកការ មន្ត្រីរាជការ ចូលរួមក្នុងទិវាមហោស្រពអង្គរ ឆ្នាំ ១៩៩៩-២០០០ តាមចំនួនកំណត់ ។

-ធ្វើកម្មវិធីលំអិត កាន់កម្មវិធី ធ្វើផ្លាកសញ្ញា បដា ពាក្យស្លោក អាហ្វីស ប៉ាណូផ្សេងៗ សំរាប់ប្រើប្រាស់តាមការចាំបាច់ ។

-ធ្វើជាសេនាធិការអោយគណៈកម្មការរៀបចំទិវាមហោស្រពអង្គរ ឆ្នាំ១៩៩៩-២០០០ គ្រប់ផ្នែកជំនាញ ។

+ **នីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងទេសចរណ៍ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ :**

-ត្រៀមលក្ខណៈដោះស្រាយថវិកា សំភារៈ បំរើការរៀបចំទិវាមហោស្រពអង្គរ ឆ្នាំ១៩៩៩-២០០០ បានទាន់ពេលវេលា ។

-ធ្វើសេចក្តីអំពាវនាវគ្រប់មជ្ឈដ្ឋានជាតិ អន្តរជាតិ សប្បុរសជន ដើម្បីសុំជួយឧបត្ថម្ភគាំទ្រជាថវិកា សំភារៈចូលរួមចំណែក បំរើការរៀបចំទិវាមហោស្រពអង្គរ ឆ្នាំ ១៩៩៩-២០០០ ។

ទទួលបានសារាចរណែនាំនេះ រាជរដ្ឋាភិបាល សង្ឃឹមថាគ្រប់ផ្នែក គ្រប់ថ្នាក់ និងចាត់តាំងអនុវត្តន៍ទទួលបានលទ្ធផលល្អប្រសើរ បំរើអោយការរៀបចំទិវាមហោស្រពអង្គរ ឆ្នាំ១៩៩៩-២០០០ សំរេចជោគជ័យ សមស្របដូចគោលបំណង និងសំណូមពរ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

# ពាក្យស្លោក

## ទិវាមហោស្រពអង្គរ

***

១- អបអរសាទរ ទិវាមហោស្រពអង្គរឆ្នាំ ១៩៩៩-២០០០

២- ជយោ ! ព្រះរាជាណាចក្រកម្ពុជា

៣- ជាតិ សាសនា ព្រះមហាក្សត្រ

៤- ជយោ ! សម្តេចព្រះបិតា វប្បធម៌ជាតិ

៥- ជយោ ! វប្បធម៌ សន្តិភាព

៦- ជាតិរស់ ព្រោះ វប្បធម៌

៧- វប្បធម៌ជាដួងព្រលឹងរបស់ជាតិ

៨- សូមថ្វាយព្រះពរ សម្តេចឪ សម្តេចម៉ែ សូមមានព្រះជន្មាយុ យឺនយូរ

៩- ជយោ ! រាជរដ្ឋាភិបាលសេដ្ឋកិច្ច

១០-ជយោ ! សម្តេចព្រះបិតា បង្រួបបង្រួម និង ផ្សះផ្សាជាតិ

១១-វប្បធម៌ជាស៊ីម៉ង់ត៍ នៃ សង្គមជាតិ

១២-វប្បធម៌ជាគ្រឹះ នៃ ការអភិវឌ្ឍន៍សង្គម

១៣-វប្បធម៌ ជា អត្តសញ្ញាណជាតិ

១៤-ជយោ ! សហស្សវត្សថ្មី នៃ សន្តិភាពនឹងការអភិវឌ្ឍន៍

១៥-ទស្សនាអង្គរ ក្នុង សហស្សវត្សថ្មីឆ្នាំ ២០០០

★★★

# III- ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៩

**ប្រកាសលេខ ៣៩៣ ប្រក.សហវ.ពដ**

**ស្តីពីការកែប្រែសមាសភាពគណៈកម្មការ**

**វាយតម្លៃដីមិនបានប្រើប្រាស់**

***

**ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ /នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ. ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ ៣១៦ ប្រក.សហវ.ពឋ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- បានឃើញសេចក្តីសំរេចលេខ ០១ សសរ.ពឋ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ ២២៤ ប្រក.សហវ.ពឋ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញសេចក្តីសំរេចលេខ ០០៥ សសរ.សហវ.ពឋ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៩៦ ស្តីពីការកំណត់តម្លៃគិតពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ ៧៥៥ ប្រក.សហវ.ពឋ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៩៦ ស្តីពីការកំណត់មេគុណសំរាប់អនុវត្តក្នុងការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ ០២៦-ប្រក.សហវ.ពឋ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៩៧ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- បានឃើញសេចក្តីសំរេចលេខ ០០៥ សសរ.សហវ.ពឋ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៩៨ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញសេចក្តីសំរេចលេខ ០០៦ សសរ.សហវ.ពឋ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- បានឃើញលិខិតលេខ ១២១ ដនស/ប ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៩៩ របស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងលិខិតលេខ ១០៥០ កសក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៩៩ របស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់

**សំរេច**

**ប្រការ ១ :** ប្រការ១ នៃប្រកាសលេខ ៣១៦ ប្រក.សហវ.ពដ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ ត្រូវបានកែប្រែដូចតទៅ :

ប្រការ ១ ( ថ្មី ) : តែងតាំង

-ឯកឧត្តម **គង់ ទិមុល** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាប្រធាន

-លោក **សៀក ទណ្ណា** អនុប្រធាននាយកដ្ឋាន សុរិយោដី នៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ អនុប្រធាន

-លោក **ចាន់ ស៊ុំ** អនុប្រធាននាយកដ្ឋាន ពន្ធដារ សមាជិក

-លោក **គាំង លាងខណ្ឌ** អនុប្រធាននាយកដ្ឋាន ទ្រព្យ រដ្ឋ សមាជិក

-លោកស្រី **សួង ហេង** ប្រធានការិយាល័យកំណត់តំបន់ នៃនាយកដ្ឋានផែនការស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ សមាជិក

-លោក **ជា ពិសិដ្ឋ** អនុប្រធានការិយាល័យតឹងទារបំណុលសារពើពន្ធ នាយកដ្ឋាន ពន្ធដារ សមាជិកទទួលបន្ទុកបូកសរុប

**ប្រការ ២ :** ឯកឧត្តម អស់លោក លោកស្រី ដូចមានរាយនាមក្នុងប្រការ១ និងគ្រប់អង្គភាព នាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និងត្រា

**គាត ឈន់**

***

រាជធានីភ្នំពេញ,ថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ប្រកាស

### ប្រកាសលេខ ១៤៣៧ ពណ.បអព ៩៩

### ស្តីពីការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញវិក្កយបត្រពាណិជ្ជកម្ម និង អាជ្ញាប័ណ្ណនាំចេញ ចំពោះទំនិញសំលៀកបំពាក់សំរាប់នាំចេញ

***

### រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/៩៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការបង្កើត ក្រសួងពាណិជ្ជកម្ម ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោង Commission Regulation ( EEC ) លេខ EEC ២៩៥៥/៩៣ ស្តីពីការផ្តល់ GSP និងការអនុគ្រោះពាណិជ្ជកម្មដល់កម្ពុជា
- យោងតាមកិច្ចព្រមព្រៀងស្តីពីទំនាក់ទំនងពាណិជ្ជកម្ម និង ការការពារកម្មសិទ្ធិខាងបញ្ញារវាងសហរដ្ឋអាមេរិក និង ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៦
- យោងតាមកិច្ចព្រមព្រៀងពាណិជ្ជកម្ម អំពីទំនិញវាយនភ័ណ្ឌធ្វើពីកប្បាស ឡែន សរសៃ សិប្បនិម្មិតធ្វើដោយដៃមនុស្ស សរសៃរុក្ខជាតិដែលគ្មានជាតិកប្បាស សរសៃល្បាយសូត្រ និងផលិតផលវាយនភ័ណ្ឌដទៃទៀត រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃសហរដ្ឋអាមេរិក
- យោងលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការអនុញ្ញាតអោយបង្កើតគណៈកម្មការត្រួតពិនិត្យបច្ចេកទេសរោងចក្រកាត់ដេរលេខ ១០០ សជណាពហ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៩៧

- យោងសេចក្តីជូនដំណឹងពីលទ្ធផលសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី២៤ ខែតុលា ឆ្នាំ ១៩៩៧
- យោងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ស្តីពីការបង្កើតគណកម្មការត្រួតពិនិត្យបច្ចេកទេសរោងចក្រកាត់ដេរលេខ ១៤១ ពណ.ពគប.ប្រក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៩៧
- យោងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មលេខ ៣៩០ ពណ.បណ.ប្រក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ស្តីពីការបង្កើតនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម
- យោងតាមប្រកាសលេខ ៣៨៨ ពណ.បណ.ប្រក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស
- យោងតាមកិច្ចព្រមព្រៀងវាយនភ័ណ្ឌដែលបានចុះហត្ថលេខាសេដ្ឋថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៩៩
- យោងតាមការចាំបាច់ក្នុងការប្រើប្រាស់វិញ្ញាបនប័ត្រ ប្រភពដើមទំនិញកម្ពុជា វិក្កយបត្រពាណិជ្ជកម្ម និង អាជ្ញាប័ណ្ណនាំចេញអោយមានប្រសិទ្ធភាព

**សំរេច**

**ប្រការ ១ :** ដើម្បីធានាអោយការផលិតសំលៀកបំពាក់សំរាប់នាំចេញ ពីកម្ពុជាប្រព្រឹត្តទៅស្របតាមបទបញ្ញត្តិប្រភពដើមទំនិញនៃប្រទេសជាគោលដៅ ជាពិសេសបណ្តាប្រទេសដែលជាសមាជិកសហគមន៍អឺរ៉ុប និង សហរដ្ឋអាមេរិក ។ ក្រសួងពាណិជ្ជកម្ម នឹងផ្តល់លក្ខណៈប្រភពដើមទំនិញរបស់កម្ពុជាតាមបែបបទដូចមានចែងក្នុងប្រការទាំងឡាយដូចខាងក្រោម ។

**ប្រការ ២ :** ការចុះបញ្ជីអ្នកនាំចេញទំនិញពីកម្ពុជា :

ការនាំចេញទំនិញសំលៀកបំពាក់ទៅកាន់ប្រទេសគោលដៅណាមួយ នៅក្រៅព្រះរាជាណាចក្រកម្ពុជានឹងអាចធ្វើទៅបានចំពោះតែផលិតករសំលៀកបំពាក់ទាំងឡាយដែលបានចុះបញ្ជីជាអ្នកនាំចេញនៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។ ផលិតករសំលៀកបំពាក់ទាំងឡាយដែលមានបំណងចុះបញ្ជី ឬ ចុះបញ្ជីឡើងវិញក្នុងនាមជាអ្នកនាំចេញត្រូវគោរពតាមបែបបទដូចតទៅ :

**១-សុពលភាពនៃការចុះបញ្ជី :**

ការចុះបញ្ជី នឹងមានសុពលភាពសំរាប់ រយៈពេល ១២ ខែ ។ បន្ទាប់ពីនោះផលិតករសំលៀកបំពាក់ណាមានបំណងចង់បន្តភាពជាអ្នកនាំចេញត្រូវមកសុំចុះបញ្ជីសារជាថ្មី ។

**២-រយៈពេលនៃការដាក់ពាក្យសុំចុះបញ្ជីសារជាថ្មី :**

អ្នកដាក់ពាក្យសុំចុះបញ្ជីដែលបានចុះបញ្ជីរួចហើយក្នុងរយៈពេល ១២ ខែកន្លងមកអាចដាក់ពាក្យសុំរបស់ខ្លួនក្នុងពេលមួយខែមុនកាលបរិច្ឆេទដែលចង់អោយការ ចុះបញ្ជីជាថ្មីរបស់ខ្លួនចូលជាធរមាន ។

**៣-ឯកសារដែលត្រូវមាននៅពេលសុំចុះបញ្ជី :**

- ពាក្យសុំដែលបានបំពេញគ្រប់គ្រាន់
- ច្បាប់ចម្លងនៃវិញ្ញាបនប័ត្រចុះបញ្ជី និង លក្ខន្តិកៈក្រុមហ៊ុនចេញអោយដោយនាយកដ្ឋាននីតិកម្មនៃក្រសួងពាណិជ្ជកម្ម ( ចំពោះក្រុមហ៊ុនដែលបានចុះបញ្ជីរួចហើយ ) ។ ឬ

- ច្បាប់ចំលងលិខិតអនុញ្ញាតវិនិយោគចេញអោយដោយ CDC និងលក្ខន្តិកៈក្រុមហ៊ុនវិនិយោគ។
- ច្បាប់ចម្លងលិខិតអនុញ្ញាតផលិតកម្មចេញអោយដោយក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- ច្បាប់ចំលងវិញ្ញាបនប័ត្ររបស់សមាជិកសមាគមផលិតករសំលៀកបំពាក់ ( សមាគមកាត់ដេរ )
- ឯកសារបញ្ជាក់ពីទីតាំងក្រុមហ៊ុន ( រោងចក្រ ) ។
- ច្បាប់ចំលងកិច្ចព្រមព្រៀងដែលផលិតករជួលរោងចក្រនៅកម្ពុជា ឬ ជួលដីដែលរោងចក្រនោះតាំងនៅ ប្រសិនបើមាន ។
- ប្រភេទសំលៀកបំពាក់សំខាន់ៗ ដែលផលិតដោយក្រុមហ៊ុន ( រោងចក្រ )។
- ចំនួនម៉ាស៊ីនដេរ ម៉ាស៊ីនផុង និង ម៉ាស៊ីនភ្ជាប់ដែលប្រើប្រាស់ក្នុងប្រតិបត្តិការផលិត ។
- លទ្ធភាពផលិតកម្មជាមធ្យមរបស់ម៉ាស៊ីនមួយគ្រឿង ក្នុងរយៈពេលមួយខែចំពោះប្រភេទសំលៀកបំពាក់សំខាន់ៗនីមួយៗ ។
- ច្បាប់ចំលងលិខិតឆ្លងដែនរបស់ម្ចាស់ក្រុមហ៊ុន ( បើជាជនបរទេស ) ឬ អត្តសញ្ញាណប័ណ្ណ (បើជាខ្មែរ ) ។
- រូបថតពីរសន្លឹករបស់ម្ចាស់ក្រុមហ៊ុន ។
- គំរូហត្ថលេខារបស់បុគ្គល ដែលបានទទួលការអនុញ្ញាតអោយចុះហត្ថលេខាជំនួសមុខអោយក្រុមហ៊ុនដោយមានការបញ្ជាក់ពីម្ចាស់ក្រុមហ៊ុនផង ។
- គំរូ ឬ រូបថតរបស់ទំនិញដែលត្រូវផលិត ។
- ក្នុងករណីដែលអ្នកដាក់ពាក្យសុំបានប្រកបរបរនេះក្នុងរយៈពេល ១២ខែ កន្លងមកហើយត្រូវបន្ថែមនូវ ពត៌មានដូចតទៅ :

* បរិមាណ និង តំលៃនៃការនាំចេញក្នុងខែនីមួយៗចំពោះឆ្នាំកន្លងមកតាមប្រភេទ MFA ពត៌មាននេះត្រូវអមភ្ជាប់ជាមួយនូវច្បាប់ចម្លងនៃវិញ្ញាបនប័ត្រដើមទំនិញកម្ពុជា និង សេចក្តីប្រកាសនាំចេញរបស់គយ ។ សំគាល់បរិមាណ និង តំលៃនៃសំពត់ ក្រណាត់ បំណែក សំលៀកបំពាក់ ដែលកាត់ពីក្រណាត់ ចាក់ ឬ ត្បាញ ផ្ទាំងចាក់ និង ប្លង់ណែតបង្គុំនៃសំលៀកបំពាក់ ( ដែលផលិតករផលិតតាមកិច្ចព្រមព្រៀង OPA ដែលបានអនុម័តរួច ) ដែលនាំចូលសំរាប់ប្រើប្រាស់ក្នុងការផលិត ទំនិញខាងលើដោយបរិមាណតាមលេខ HS និង តាមខែនីមួយៗ ។ ទិន្នន័យទាំងនេះ ត្រូវអម ភ្ជាប់ជាមួយដោយច្បាប់ចំលងនៃសេចក្តីបញ្ជាក់ នាំចូលរបស់គយ ព្រមទាំងវិក្កយបត្ររបស់អ្នក ផ្គត់ផ្គង់វត្ថុធាតុដើមទាំងនោះផង ។

**៤- ការផ្ទៀងផ្ទាត់បញ្ជាក់ទិន្នន័យរបស់ឯកសារ :**

អ្នកដាក់ពាក្យសុំចុះបញ្ជី ត្រូវបង្កលក្ខណៈងាយស្រួលដល់មន្ត្រី នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ដែលចុះទៅធ្វើការត្រួតពិនិត្យជាក់ស្តែងដល់ទីតាំងផលិត ដើម្បីធ្វើការផ្ទៀងផ្ទាត់ទិន្នន័យ ដែលប្រកាសដោយអ្នកស្នើសុំចុះបញ្ជី ។

**៥- រយៈពេលកំណត់ចំពោះមេមចុះបញ្ជី ៖**

- ការចុះបញ្ជីត្រូវបញ្ចប់ក្នុងរយៈពេល ៧ថ្ងៃ បន្ទាប់ពីអ្នកដាក់ពាក្យសុំបាន ដាក់ជូនពិនិត្យ ឬ ដាក់ជូនពិនិត្យឡើងវិញនូវឯកសារទាំងឡាយ ដែលគ្រប់គ្រាន់ ។
- នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ត្រូវជូនដំណឹង ដល់អ្នកដាក់ពាក្យសុំ ក្នុងរយៈពេល ៣ ថ្ងៃ ធ្វើការ ចំពោះសំណើដែលពុំទាន់មានឯកសារគ្រប់គ្រាន់ ។
- នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម អាចបដិសេធពាក្យស្នើសុំបានតែម្តងគត់ ចំពោះហេតុផល ដូចខាងលើនេះ លើកលែងតែការដាក់ពាក្យជូនពិនិត្យនៅតែពុំទាន់បានកែតម្រូវកង្វះខាតពីខាងដើម ។

**៦- ការកែតម្រូវពត៌មាននៃការចុះបញ្ជី ៖**

អ្នកនាំចេញដែលបានចុះបញ្ជីអាច នឹងធ្វើការកែតម្រូវនៅពេលណាមួយក៏បាន ក្នុងរយៈពេលចុះបញ្ជីរបស់ខ្លួន នូវរាល់ពត៌មានទាំងឡាយ ដែលបានចុះបញ្ជីរួចហើយ ដែលពត៌មានទាំងនោះទាក់ទងនឹង ៖

- ប្រភេទសំលៀកបំពាក់ដែលផលិត
- ម៉ាស៊ីនដេរក្នុងប្រតិបត្តិការ
- លទ្ធភាពផលិត ជាមធ្យមប្រចាំខែ ចំពោះម៉ាស៊ីនីមួយៗ តាមប្រភេទសំលៀកបំពាក់នីមួយៗ នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម នឹងធ្វើការផ្ទៀងផ្ទាត់ ការកែប្រែនេះ តាមការត្រួតពិនិត្យជាក់ស្តែងមុននឹងធ្វើការកែតម្រូវជូន ។

ប្រការ ៣ : ឯកសារជាភស្តុតាង នៃការនាំចូលវត្ថុធាតុដើមសំលៀកបំពាក់ ៖

អ្នកនាំចេញសំលៀកបំពាក់ ដែលចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ត្រូវផ្តល់ជូនពិនិត្យនូវឯកសារដូចតទៅក្នុងរយៈពេល ១២ ខែ នៃការចុះបញ្ជីរបស់ខ្លួន :

**១- ការបញ្ជាក់ពីសារពើភ័ណ្ឌវត្ថុធាតុដើម :**

- រៀងរាល់ខែផលិតករត្រូវផ្តល់ជូន នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និង នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស នូវឯកសារបញ្ជាក់ពីសារពើភ័ណ្ឌវត្ថុធាតុដើមសំខាន់ៗ ដែលប្រើប្រាស់ក្នុងការផលិតសំលៀកបំពាក់រួមមាន អំបោះ ក្រណាត់ បំណែកបង្គុំសំលៀកបំពាក់ ដែលកាត់ពីក្រណាត់ចាក់ ឬត្បាញ ផ្ទាំងចាក់ និង ឬ ផ្នែកបង្គុំសំលៀកបំពាក់ ឬផ្ទាំងចាក់ ( ក្នុងករណីដែលអ្នកនាំចេញប្រតិបត្តិការតាមបែបបទ OPA ) ។

២- ច្បាប់ចំលងឯកសារ ផ្ទៀងផ្ទាត់ការនាំចូលវត្ថុធាតុដើមក្នុងខែដែលកំពុងស្ថិតនៅក្រោមការពិនិត្យឡើងវិញ : ឯកសារទាំងនេះត្រូវរួមមាន Bill of Lading ( BL ) និង សេចក្តីប្រកាសរបស់គយ ។

៣- សន្លឹកចំលងនៃវិក្កយប័ត្រប្រភពដើមទំនិញ ដែលបញ្ជាក់ទៅលើប្រភពដើមរបស់វត្ថុដើមនាំចូល ដែលចេញអោយដោយអាជ្ញាធរមានសមត្ថកិច្ច នៃបណ្តាប្រទេសជាសមាជិក ASEAN ឯកសារ ទាំងនេះត្រូវដាក់ជូនពិនិត្យដោយអ្នកនាំចេញទាំងឡាយណា ដែលមានបំណង

ស្នើសុំអាជ្ញាប័ណ្ណនាំចេញ និងវិញ្ញាបនប័ត្រប្រភពដើមទំរង់ A របស់កម្ពុជាដើម្បី នាំចេញទៅកាន់ប្រទេសដែលជា សមាជិក សហគមន៍អឺរ៉ុប ( EU ) ។

ប្រការ ៤ : ទំរង់របស់វិញ្ញាបនប័ត្រ

ទំនិញសំលៀកបំពាក់ដែលផលិតនៅកម្ពុជាអាចស្នើសុំវិញ្ញាបនប័ត្រតាមទំរង់ដូចខាងក្រោម :

១- វិញ្ញាបនប័ត្រប្រភពដើមទំរង់ធម្មតា ចំពោះតែករណីសំលៀកបំពាក់នាំចេញដែលមិនមែនធ្វើឡើងតាមបែបបទ GSP ។

២- វិញ្ញាបនប័ត្រប្រភពដើមទំនិញកម្ពុជាទំរង់ A ចំពោះទំនិញនាំចេញដែលធ្វើឡើងក្នុងគោលបំណងអោយរួចពន្ធគយនៅទីផ្សារ EU តាមបែបបទ GSP ។

៣- វិញ្ញាបនប័ត្រប្រភពដើមទំនិញកម្ពុជាទំរង់ A ត្រូវបានបំពេញបន្ថែមនូវកំណត់សំគាល់ដូចតទៅ :

- Article 72 B Regional Cumulation ចំពោះទំនិញនាំចេញទៅប្រទេសជាសមាជិក EU ដែលមានបំណងអោយរួចពន្ធគយនៅទីផ្សារ EU ។

៤- ទិដ្ឋាការ (VISA) : អនុវត្តចំពោះទំនិញនាំចេញទៅសហរដ្ឋអាមេរិក (USA)

៥- អាជ្ញាប័ណ្ណនាំចេញ (Export Licence) :

ក-ករណីទំនិញនាំចេញទៅប្រទេសCanada ( បែបបទទាំងឡាយត្រូវបាន អនុវត្តដោយនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម )

ខ-ករណីទំនិញនាំចេញទៅ EU ប្រភេទ ៤,៥,៦,៧,៨,១៥,២១,២៤,៧៣ តាមកិច្ចព្រមព្រៀងវាយនភ័ណ្ឌ ដែលបានចុះហត្ថលេខានៅថ្ងៃទី០៣-០២-១៩៩៩ ( បែបបទនេះអនុវត្តដោយនាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស )

ប្រការ ៥ : ក- ខ្លឹមសារវិញ្ញាបនប័ត្រប្រភពដើមទំនិញកម្ពុជា វិក្កយបត្រពាណិជ្ជកម្ម អាជ្ញាប័ណ្ណនាំចេញ (Canada)។

ត្រូវវិញ្ញាបនប័ត្រប្រភពដើមទំនិញទាំងឡាយទោះជាមានទំរង់បែបណាក្តីក៏ដោយក៏ត្រូវបញ្ជាក់ នូវពត៌មានមួយចំនួនខាងក្រោម :

- ឈ្មោះ និង អាស័យដ្ឋានរបស់អ្នកនាំចេញ
- ឈ្មោះ និង អាស័យដ្ឋានរបស់អ្នកនាំចូល
- ប្រទេសដែលជាគោលដៅ
- លំអិតផ្លូវដឹកជញ្ជូន
- បរិមាណនៃសំលៀកបំពាក់នីមួយៗ បញ្ជាក់ពីលេខកូដ HS
- តម្លៃតាមប្រភេទទំនិញនីមួយៗ និង តំលៃសរុបទំនិញនាំចេញ ។
- សេចក្តីប្រកាសរបស់អ្នកនាំចេញ ដែលបញ្ជាក់ថាទំនិញបានផលិតដោយសមស្របតាមបទបញ្ញត្តិប្រភពដើមទំនិញ ។
- សេចក្តីបញ្ជាក់ថាទំនិញមានប្រភពដើមនៅកម្ពុជាដោយមានចុះហត្ថលេខា បោះត្រា និង ចោះលេខសំគាល់របស់ក្រសួងពាណិជ្ជកម្ម ។

ខ-ខ្លឹមសារអាជ្ញាប័ណ្ណនាំចេញផលិតផលវាយនភ័ណ្ឌពីកម្ពុជាទៅកាន់ EU :

អាជ្ញាប័ណ្ណនាំចេញផលិតផលវាយនភ័ណ្ឌពីកម្ពុជាដូចមានចែងក្នុងប្រការ ៥ ចំណុច ៥.១ ត្រូវមានបញ្ជាក់ពត៌មានមួយចំនួនដូចខាងក្រោម :

- ឈ្មោះ និង អាសយដ្ឋានរបស់អ្នកនាំចេញ
- លេខអាជ្ញាប័ណ្ណនាំចេញ
- ឆ្នាំនាំចេញ
- ប្រភេទ (Category)
- ឈ្មោះ និង អាសយដ្ឋានរបស់អ្នកទិញទំនិញពីកម្ពុជា
- ប្រទេសដែលជាប្រភពដើមទំនិញ : កម្ពុជា
- ប្រទេសគោលដៅទំនិញទៅដល់
- អត្តសញ្ញាណដឹកជញ្ជូន ថ្ងៃ ខែ ឆ្នាំ ទំនិញចេញពីកម្ពុជា និងទីកន្លែងផ្ទុកទំនិញ
- បញ្ជាក់ពត៌មានផ្សេងៗ
- បញ្ជាក់ពត៌មានអំពីគំរូ : មេជាប្រភេទ ចំនួនរួម ប្រភេទវេចខ្ចប់ អាចពិតជាឡូ ឬកាតុងក៏បាន ។
- បរិមាណនៃប្រភេទទំនិញ ដោយបញ្ជាក់ខ្នាតអោយបានច្បាស់លាស់ ចំពោះប្រភេទ Categories : ៤,៥,៦,៧,៨,១៥,២១, ខ្នាតគិតជា Pieces រីឯចំពោះប្រភេទ Categories : ២៨,៧៣ ខ្នាតគិតជា Kg ។
- តំលៃសរុប រូបិយប័ណ្ណគិតជាខ្នាតណាមួយក៏បាន ដោយយោងទៅលើកិច្ចសន្យា ។
- ចុះហត្ថលេខា ត្រា និង បោះលេខសំគាល់ផ្សេងៗ របស់ក្រសួងពាណិជ្ជកម្ម ។
- ឈ្មោះនិងអាសយដ្ឋានរបស់នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស នៃក្រសួងពាណិជ្ជកម្ម សុពលភាពនៃអាជ្ញាប័ណ្ណនាំចេញ : សុពលភាពមានរយៈពេល ៦ ខែក្រោយការបើចេញ នៃការចេញអាជ្ញាប័ណ្ណ ។

ប្រការ ៦ :

១- បែបបទនៃការចេញវិញ្ញាបនប័ត្រប្រភពដើមទំនិញកម្ពុជា , វិក្កយបត្រពាណិជ្ជកម្មអាជ្ញាប័ណ្ណនាំចេញ :

ក-បែបបទនៃការចេញ វិញ្ញាបនប័ត្រប្រភពដើមទំនិញ , វិក្កយបត្រពាណិជ្ជកម្ម និងអាជ្ញាប័ណ្ណនាំចេញ ( Canada ) :

$ក_1$ : ការដាក់ពាក្យស្នើ :

- ឯកសារភ្ជាប់រួមមាន :
  - + វិក្កយបត្រ ( INVOICE )
  - + បញ្ជីទំនិញ ( Packing List )
  - + កិច្ចសន្យាទិញ លក់ និង ឬ ប័ណ្ណបញ្ជាទិញរបស់អ្នកទិញនៅបរទេស

- វិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម ចេញដោយនាយកដ្ឋានឧស្សាហកម្ម រ៉ែ និង ថាមពល ។
- ពង្រាងវិញ្ញាបនប័ត្រប្រភពដើមទំនិញ វិក្កយបត្រពាណិជ្ជកម្ម និង អាជ្ញាប័ណ្ណនាំចេញ (Canada) ដែលទាក់ទងផលប់ទំនិញនាំចេញ ។ ដើម្បីធានានូវភាព ត្រឹមត្រូវនៃបរិយាយប្រភេទរបស់ ផលិតផល ដោយផ្អែកលើលេខកូដនៃប្រព័ន្ធ HS អ្នកដាក់ពាក្យសុំត្រូវផ្តល់ជូនផងដែរនូវលេខកូដនេះ ។

នៅក្នុងពង្រាងវិញ្ញាបនប័ត្រប្រភពដើមទំនិញវិក្កយបត្រពាណិជ្ជកម្ម និង អាជ្ញាប័ណ្ណនាំចេញ ( Canada ) នោះត្រូវបរិយាយនូវប្រភេទ ( Category ) ។

- ប័ណ្ណទទួលប្រាក់របស់នាយកដ្ឋានរដ្ឋបាលនៃក្រសួងពាណិជ្ជកម្ម បញ្ជាក់ពីការបង់កំរៃ : វិញ្ញាបនប័ត្រចំនួន ៣០ ដុល្លារ ចំពោះវិញ្ញាបនប័ត្រទំរង់ធម្មតា ឬ ៥០ ដុល្លារចំពោះវិញ្ញាបនប័ត្រទំរង់ A និង ៥០ ដុល្លារ ចំពោះអាជ្ញាប័ណ្ណនាំចេញ ( Canada ) ។
- វិក្កយបត្រពាណិជ្ជកម្ម ចំនួន ១២០.០០០ រៀល ( មួយរយម្ភៃពាន់រៀលគត់ ) ។

ក₂-<u>ការចេញវិញ្ញាបនប័ត្រប្រភពដើមទំនិញវិក្កយបត្រពាណិជ្ជកម្មនិងអាជ្ញាប័ណ្ណនាំចេញ(Canada)</u> :

- ក្រោយពីបានទទួលពាក្យស្នើសុំវិញ្ញាបនប័ត្រប្រភពដើមទំនិញ ដោយមានភ្ជាប់ឯកសារអមដូចបានបញ្ជាក់ជូននៅក្នុងចំណុច ១ ខាងលើរួមទាំងវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម ( C/P ) នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ត្រូវចេញលិខិតអនុញ្ញាតនាំចេញបណ្តោះអាសន្ន (Temporary Export Authorization) ជូនដល់ក្រុមហ៊ុនដែលបានដាក់ពាក្យសុំ ដើម្បីធ្វើការនាំចេញទំនិញរបស់ខ្លួនសិន ទន្ទឹម នឹងការចុះត្រួតពិនិត្យទំនិញតាមលក្ខណៈបច្ចេកទេស និង ពិនិត្យសង្វាក់ផលិតកម្មជាក់ស្តែងនៅទីតាំងរោងចក្រ ។
- លិខិតអនុញ្ញាតនាំចេញបណ្តោះអាសន្ននេះ ត្រូវមានខ្ទីមសារ និងលក្ខណៈចាំបាច់ផ្សេងៗ ដូចវិញ្ញាបនប័ត្រប្រភពដើមទំនិញដែរ ។ លិខិតនេះត្រូវធ្វើឡើងជា ៤ ច្បាប់គឺច្បាប់ដើម ( Original ) ច្បាប់ចម្លង ( Duplieate ) ច្បាប់ទី ៣ ( Triplicate ) និងច្បាប់ទី ៤ ( Quadruplicate ) ។ ពេលដែលទំនិញត្រូវបាននាំចេញរួចហើយ អ្នកនាំចេញត្រូវភ្ជាប់ លិខិតអនុញ្ញាតនាំចេញបណ្តោះអាសន្ននេះជាមួយនឹងឯកសារនាំចេញដូចតទៅ :

ក- អញ្ញត្តិប័ណ្ណដឹកជញ្ជូន (Bill of Lading Original Copy )

ខ- លិខិតអនុញ្ញាតនាំចេញរបស់គយ

( Custom Export Declaration Original Copy )

គ- វិញ្ញាបនប័ត្របញ្ជាក់បរិមាណរបស់កាំកុងត្រូល

( Camcontrol Certificate of Quantity- Original Copy )

រួចបញ្ជូនមកនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មដើម្បីពិនិត្យ និង ចេញវិញ្ញាបនប័ត្រប្រភពដើមទំនិញ ឬ វិក្កយបត្រពាណិជ្ជកម្ម ឬ អាជ្ញាប័ណ្ណនាំចេញ ( Canada ) ។ ទំនិញនាំចេញមុនពេលបញ្ចូល Container ដែលត្រួតពិនិត្យដោយមន្ត្រីកាំកុងត្រូល និងមន្ត្រីគយ រដ្ឋាករ គឺត្រូវអនុវត្តផ្ទាល់នៅរោងចក្រ ។ ក្នុងករណីម្ចាស់ទំនិញមិនគោរពតាមទិសដៅណែនាំនេះ ក្រសួង

ពាណិជ្ជកម្ម និង សមត្ថកិច្ចមានភារកិច្ចអនុវត្ត មិនទទួលស្គាល់ការយឺតយ៉ាវ ឬ បញ្ហាផ្សេងៗ ដែលកើតឡើងជាយថាហេតុ ។

ខ-បែបបទនៃការចេញអាជ្ញាប័ណ្ណនាំចេញផលិតផលដោយមានកូតាកម្ពុជា :

ខ₁- ការដាក់ពាក្យសុំ :

- ពាក្យសុំដែលក្នុងនោះបញ្ជាក់ថាទំនិញពាក់ព័ន្ធមានប្រភពដើមពីកម្ពុជា
- ភ្ជាប់ជាមួយនេះ :

* វិក្កយបត្រ ( Invoice )

* បញ្ជីទំនិញ ( Packing List )

* កិច្ចសន្យាទិញ-លក់ និង ឬប័ណ្ណបញ្ជាទិញរបស់អ្នកទិញនៅបរទេស

- ពង្រាងអាជ្ញាប័ណ្ណនាំចេញដែលមានចុះឈ្មោះទំនិញនាំចេញ ។ ដើម្បីធានានូវភាពត្រឹមត្រូវនៃការចាត់ថ្នាក់របស់ផលិតផល តាមការធ្វើចំណាត់ថ្នាក់លេខកូដ HS អ្នកដាក់ពាក្យសុំត្រូវផ្តល់ជូនផងដែរ នូវលេខកូដនេះ ។ នៅក្នុងពង្រាងអាជ្ញាប័ណ្ណនាំចេញទំនិញនោះ ត្រូវបរិយាយនូវប្រភេទ ( Category ) ឱ្យបានត្រឹមត្រូវ ។
- ប័ណ្ណទទួលប្រាក់របស់នាយកដ្ឋានរដ្ឋបាល នៃ ក្រសួងពាណិជ្ជកម្ម បញ្ជាក់ពីការបង់ថ្លៃអាជ្ញាប័ណ្ណនាំចេញ ចំនួន ១៥.០០០ រៀល ( ដប់ប្រាំពាន់រៀលគត់ ) ។

ខ₂- ការចេញអាជ្ញាប័ណ្ណនាំចេញផលិតផលដោយមានកូតា :

ចំពោះការនាំចេញទៅសហរដ្ឋអាមេរិក ក្នុងប្រភេទ Categories ( 4,5,6,7,8,15,21,28,73 ) អ្នកនាំចេញក្រោយពីបានធ្វើការនាំចេញទំនិញរួចហើយ ត្រូវភ្ជាប់ឯកសារមួយចំនួនដូចខាងក្រោម :

- លិខិតអនុញ្ញាតនាំចេញបណ្តោះអាសន្ន ( Temporary Export Authorization )
- អញ្ញត្តិប័ណ្ណដឹកជញ្ជូន ( Bill of Lading )
- លិខិតអនុញ្ញាតនាំចេញរបស់គយ ( Custom Export Declaration )
- វិញ្ញាបនប័ត្របញ្ជាក់បរិមាណរបស់កាំកុងត្រូល ( Camcontrol Certificate of Quantity )

ឯកសារទាំងនេះ ត្រូវបញ្ជូនមកនាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ដើម្បីសុំអាជ្ញាប័ណ្ណនាំចេញជាមុនសិន មុននឹងបញ្ជូនទៅ នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម សុំវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ ( Certificate of Origine ) ។

**ប្រការ ៧ : ទោសទណ្ឌ និង ការដាក់វិន័យ :**

១-អ្នកនាំចេញទាំងឡាយណា ដែលបានប្រព្រឹត្តសកម្មភាពផ្ទុយនឹងប្រកាសលេខ ៣៥០ ពណ.ករ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៩៦ និងប្រការនានានៃប្រកាសនេះ ត្រូវទទួលការដាក់ពិន័យដូចខាងក្រោម :

១-១ ការបំពានលើកទី ១ : ពិន័យ US$ 10,000 ( ដប់ពាន់ដុល្លារអាមេរិក ) និង ឬផ្អាកការផ្តល់វិញ្ញាបនប័ត្រប្រភពដើមទំនិញនិងវិក័យប័ត្រពាណិជ្ជកម្ម ឬ អាជ្ញាប័ណ្ណនាំចេញចំនួន ១៥ ថ្ងៃធ្វើការ ។

១-២ ការបំពានលើកទី ២ : ពិន័យ US$ 50,000 ( ហាសិបពាន់ដុល្លារអាមេរិក ) និងផ្អាកការផ្តល់វិញ្ញាបនប័ត្រប្រភពដើមទំនិញ និងវិក្កយបត្រពាណិជ្ជកម្ម ឬ អាជ្ញាប័ណ្ណនាំចេញចំនួន ៣ ខែ ។

១-៣ ការបំពានលើកទី ៣ : ព្យួរ ឬ លុបចោលការចុះបញ្ជី ។

២-អ្នកនាំចេញទាំងឡាយណា ដែលមានភស្តុតាងបញ្ជាក់ថាបានប្រព្រឹត្តជាមួយផលិតករបរទេសក្នុងការសុំអាជ្ញាប័ណ្ណនាំចេញ វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ វិក្កយបត្រពាណិជ្ជកម្ម ពីកម្ពុជា ដើម្បីនាំចេញទំនិញដែលផលិតនៅកន្លែងផ្សេងៗ ក្រៅពីរង្វង់ដែនដីរបស់កម្ពុជាទៅកាន់ប្រទេសទី ៣ ហើយដែលប្រទេសនោះបានបដិសេធមិនអោយធ្វើការនាំចូលដោយហេតុផលការរំលោភកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃប្រទេសរបស់ផលិតករនោះ និងរដ្ឋាភិបាលនៃប្រទេសទី ៣ អ្នកនាំចេញនោះអាចនឹងត្រូវដកសិទ្ធិចុះបញ្ជីតាមការសំរេចរបស់ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម ។

៣-មន្ត្រីនៃក្រសួងពាណិជ្ជកម្មដែល :

៣-១ ប្រព្រឹត្តជាមួយផលិតករផលិតសំលៀកបំពាក់ ដើម្បីប្រព្រឹត្តបទល្មើសបំពាន និងប្រការនៃសេចក្តីប្រកាសនេះ ។

៣-២ ព្យាយាមជំរិតទារប្រាក់ដែលមិនបានចែងក្នុងប្រកាសនេះដោយការគំរាមកំហែង ជារូបភាពជាក់ស្តែង ឬរំពឹងទុកថាយឺតយ៉ាវក្នុងការចេញអាជ្ញាប័ណ្ណនាំចេញវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញពីកម្ពុជា វិក្កយបត្រពាណិជ្ជកម្ម និងអាជ្ញាប័ណ្ណនាំចេញដោយគ្មានមូលហេតុត្រឹមត្រូវ ។

មន្ត្រីនោះត្រូវទទួលពិន័យទៅតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការ នៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៨ :** រាល់ឯកសារទាំងឡាយណា ដែលផ្ទុយពីសេចក្តីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៩ :** អគ្គនាយកបច្ចេកទេស អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មក្រៅប្រទេស ប្រធាននាយកដ្ឋានកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្មត្រូវអនុវត្ត ប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ១០ :** ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ចម ប្រសិទ្ធ**

★★★

## ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៩

**ប្រកាសលេខ ៤៩៤ ឧក.ប្រក**

***

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណា ព្រះបាទសម្តេច នរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៩៩១/៩៩ គ.វ.ក ចុះថ្ងៃទី០១-៣-១៩៩៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិតលេខ ៩៩២ ប.ស្ថ ចុះថ្ងៃទី០៦-៤-១៩៩៩ របស់ក្រសួងបរិស្ថាន
- បានឃើញលិខិតលេខ ២២០០ សអ.ស ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ១៩៩៨ របស់សាលាក្រុងភ្នំពេញ ស្តីពីការអនុញ្ញាតអោយសាងសង់អគារកាត់ដេរ ។
- យោងពាក្យស្នើររបស់ក្រុមហ៊ុន សិនហ្ស ( ខាំបូឌា ) តិចស្ទែល លីមីធីត ចុះថ្ងៃទី៤-៥-១៩៩៩

**សំរេច**

**ប្រការ ១ :** អនុញ្ញាតអោយក្រុមហ៊ុន សិនហ្ស (ខាំបូឌា) តិចស្ទែល លីមីធីត (SHENZHOU (CAMBO DIA) TEXTILE Co..., LTD ) តំណាងដោយលោក MABAOXING សញ្ជាតិ ចិន ភេទប្រុស អាយុ ៦៦ ឆ្នាំ អាសយដ្ឋាន # ២០២ Road Uay Eang Sin Chhun Waiyang New, Beicang Ninghbo, Zhejiang , CHINA កាន់លិខិតឆ្លងដែនលេខ PCHN 144398777 ចុះថ្ងៃទី 22-5-1997 បង្កើត " រោងចក្រកាត់ដេរសំលៀកបំពាក់ នាំចេញ " ដែលមានឈ្មោះថា " រោងចក្រកាត់ដេរ សិនហ្ស (ខាំបូឌា) តិចស្ទែល " មានទីតាំងស្ថិតនៅ ដីឡូត៍លេខ ៤ និងលេខ ១ កាត់ជ្រុងផ្លូវលេខ ៣៦១.៦៤០.៣៥៩ សង្កាត់ច្បារអំពៅទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

**ប្រការ ២ :** ការបង្កើតរោងចក្រនេះ ក្រុមហ៊ុនត្រូវធ្វើទៅតាមប្លង់ និង គំរោងសិក្សាសមិទ្ធលទ្ធភាពបង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

**ប្រការ ៣ :** ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាពផលិតផលហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ ។

**ប្រការ ៤ :** រោងចក្រនេះត្រូវបានអនុញ្ញាតឲ្យ " កាត់ ដេរសំលៀកបំពាក់ " ទៅតាមគំរូ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

**ប្រការ ៥ :** រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាបនបត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

**ប្រការ៦ :** ក្រុមហ៊ុនត្រូវលើកបង្ហាញ " ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួននៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

**ប្រការ ៧ :** ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ធ្ងន់ធ្ងរ នឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

**ប្រការ ៨ :** ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុនសិនហ្សូ ( ខាំបូឌា ) តិចស្ទែល លីមីធីត ត្រូវអនុវត្ត ប្រកាសនេះតាមមុខការរៀងៗខ្លួន ។

**ប្រការ ៩ :** ប្រកាសនេះមានអនុភាព គតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និងត្រា

ស៊ុយ សែម

***

## ៤-នីស្តីការរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៩

### ប្រកាសលេខ ២២ ប្រក

### ស្តីពីការបញ្ចូលក្របខ័ណ្ឌមន្ត្រីរាជការ

***

### រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- យោងប្រកាសលេខ ៣៣៩ ប្រក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៩៩ របស់ក្រសួងមហាផ្ទៃ

- តាមការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : ត្រូវបានបញ្ចូលក្នុងក្របខ័ណ្ឌ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ នូវមន្ត្រីរាជការចំនួន ២៧៤ នាក់ មកពីមន្ទីររៀបចំក្រុង និងសំណង់ រាជធានីភ្នំពេញ ដូចមានឈ្មោះក្នុង បញ្ជីឧបសម្ព័ន្ធ នៃប្រកាសនេះ ។

ប្រការ ២ : អស់លោក លោកស្រី នាងកញ្ញា ទាំង ២៧៤ នាក់ ដែលមានឈ្មោះក្នុងបញ្ជីឧបសម្ព័ន្ធនៃប្រការ១ ត្រូវបានចាត់អោយទៅបំរើការងារក្នុងអង្គភាពដើមដដែល ។

ប្រការ ៣ : នាយកខុទ្ទកាល័យ អង្គភាពពាក់ព័ន្ធ ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ និងអស់លោក លោកស្រីនាងកញ្ញា ទាំង ២៧៤ នាក់ ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
អ៊ឹម ឈុនលឹម

★★★

## ប្រកាសលេខ ២៣៣ ដន.ស.ប្រ

### បញ្ជីឧបសម្ព័ន្ធ នៃប្រកាសលេខ ២២ ប្រក ចុះថ្ងៃទី១៨ ខែ ឧសភា ឆ្នាំ១៩៩៩ ស្តីពីការបញ្ចូលក្របខ័ណ្ឌមន្ត្រីរាជការ មកបំរើការងារក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

***

| ល.រ | នាម និង គោត្តនាម | ភេទ | ឆ្នាំកំណើត | មុខងារ | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ស៊ិន សុខ | ប | ១៩៥៦ | នាយកមន្ទីរ | |
| ២ | ចៅ ខួង | ប | ១៩៥៦ | នាយករង | |
| ៣ | យស ឆោមណារ៉ាឌី | ប | ១៩៥២ | នាយករង | |
| ៤ | ហួ យូ | ប | ១៩៥០ | ប្រធានការិយាល័យ | |
| ៥ | លូ ផាត | ប | ១៩៤៧ | អនុប្រធានការិយាល័យ | |
| ៦ | គីង អៀន | ប | ១៩៥៥ | បុគ្គលិក | |
| ៧ | ណៅ អាន | ប | ១៩៥៥ | - | |
| ៨ | អ៊ឹម ម៉ៅ | ស | ១៩៤១ | - | |
| ៩ | ប៉ែន សុគន្ធារី | ស | ១៩៥៧ | - | |
| ១០ | បេន ទូច | ប | ១៩៦៩ | - | |
| ១១ | ប្រាក់ ជ្រុន | ប | ១៩៥៥ | - | |

| | | | | | |
|---|---|---|---|---|---|
| ១២ | ព្រុំ ស្ដី | ប | ១៩៦៨ | បុគ្គលិក | |
| ១៣ | ម៉ែន សុភ័ណ្ឌារ៉ា | ស | ១៩៥៧ | អនុប្រធានការិយាល័យ | |
| ១៤ | តិប សោភា | ស | ១៩៦៧ | បុគ្គលិក | |
| ១៥ | សុខ ផាច | ស | ១៩៥៧ | - | |
| ១៦ | ម៉ម ផ្ទួងសុជាតិ | ប | ១៩៥៧ | - | |
| ១៧ | ឌិម វណ្ណារី | ស | ១៩៥៧ | បុគ្គលិក | |
| ១៨ | ឈុន ខេមរិន្ទ | ប | ១៩៥៨ | - | |
| ១៩ | នូ បូផានី | ស | ១៩៥៣ | - | |
| ២០ | ចាន់ រ៉ាវី | ស | ១៩៥៧ | - | |
| ២១ | ប៊ុន ផលា | ស | ១៩៥៧ | - | |
| ២២ | ចេង នារីរតន៍ | ស | ១៩៥៩ | - | |
| ២៣ | លឹម បុត្តម៉ានី | ស | ១៩៥៩ | បុគ្គលិក | |
| ២៤ | ព្រុំ ផា | ស | ១៩៦៥ | - | |
| ២៥ | ហ៊ួត សុគន្ធី | ស | ១៩៦៧ | - | |
| ២៦ | សុខ ហេង | ប | ១៩៥៦ | - | |
| ២៧ | ងួន សារហ៊ឿ | ប | ១៩៧២ | - | |
| ២៨ | ពេជ្រ គឹមហ៊ាន | ប | ១៩៥៥ | - | |
| ២៩ | ពេញ សាឈឿន | ប | ១៩៥២ | ប្រធានការិយាល័យ | |
| ៣០ | កុយ វណ្ណធឿន | ប | ១៩៥០ | អនុប្រធានការិយាល័យ | |
| ៣១ | ប៊ុត លី | ប | ១៩៦៧ | បុគ្គលិក | |
| ៣២ | អាំង សុវណ្ណារិទ្ធ | ប | ១៩៦៧ | - | |
| ៣៣ | សេង ឫទ្ធី | ប | ១៩៧០ | - | |
| ៣៤ | ពឹង រតនៈ | ប | ១៩៦៩ | - | |
| ៣៥ | នៅ ផល្លា | ប | ១៩៧១ | - | |
| ៣៦ | ហួន ផល្លី | ប | ១៩៦៧ | - | |
| ៣៧ | ផាន់ ច័ន្ទមុនី | ប | ១៩៦៦ | - | |
| ៣៨ | ម៉ែន វុធនី | ប | ១៩៦២ | - | |
| ៣៩ | គួ ឥសិទ្ធ | ប | ១៩៦០ | - | |
| ៤០ | ស៊ួន វី | ស | ១៩៦៩ | - | |
| ៤១ | ហ៊ុំ គាង | ប | ១៩៦៧ | - | |
| ៤២ | ជុំ វីរៈ | ប | ១៩៧១ | - | |

| | | | | | |
|---|---|---|---|---|---|
| ៤៣ | ហ៊ាង ម៉ាប់ | ប | ១៩៧៣ | បុគ្គលិក | |
| ៤៤ | សួរ ផារ៉ា | ប | ១៩៦៧ | - | |
| ៤៥ | អ៊ុំ ធន់ | ប | ១៩៦៩ | - | |
| ៤៦ | ទឹម ប៊ុនធឿន | ប | ១៩៦៨ | - | |
| ៤៧ | គោ ច័ន្ទបុប្ផា | ស | ១៩៦៧ | - | |
| ៤៨ | ងិន ចន្ធឿន | ប | ១៩៧០ | បុគ្គលិក | |
| ៤៩ | ពេជ្រ សុវណ្ណា | ស | ១៩៦៥ | - | |
| ៥០ | ឌី សានិត | ប | ១៩៥៨ | - | |
| ៥១ | អ៊ុង ធើត | ប | ១៩៥៦ | - | |
| ៥២ | មាស ពិរុណ | ប | ១៩៥៩ | - | |
| ៥៣ | អួង សារ៉ាន់ | ប | ១៩៥៧ | បុគ្គលិក | |
| ៥៤ | មុត ភិរម្យ | ប | ១៩៦៨ | - | |
| ៥៥ | ផេង និស័យ | ប | ១៩៧០ | - | |
| ៥៦ | ប៉ុក បញ្ញាធិ | ប | ១៩៧១ | - | |
| ៥៧ | លឹម វាសនា | ប | ១៩៦៩ | - | |
| ៥៨ | អ៊ុក នរឫទ្ធិ | ប | ១៩៦៩ | - | |
| ៥៩ | គង់ ប៉ូច | ប | ១៩៦៨ | - | |
| ៦០ | នួស្លា សត្យា | ប | ១៩៧០ | - | |
| ៦១ | ជា សែ | ប | ១៩៧០ | - | |
| ៦២ | ប៊ុន ឡុង | ប | ១៩៦៩ | - | |
| ៦៣ | ពេក ប៊ុនលាំង | ប | ១៩៦៨ | - | |
| ៦៤ | ហៃ វណ្ណច័ន្ទ | ប | ១៩៧១ | - | |
| ៦៥ | ភន សុមនា | ស | ១៩៧០ | - | |
| ៦៦ | ម៉េង ប៊ុណ្ណារិទ្ធ | ប | ១៩៧១ | - | |
| ៦៧ | ឈួន ស៊ាងឡុន | ប | ១៩៥០ | អនុប្រធានការិយាល័យ | |
| ៦៨ | រ៉ាង សុខន | ស | ១៩៥៦ | បុគ្គលិក | |
| ៦៩ | សុទ្ធា ផល្លី | ស | ១៩៥៩ | - | |
| ៧០ | ហៃ សុភី | ស | ១៩៥១ | - | |
| ៧១ | សរិត សន | ប | ១៩៥៥ | - | |
| ៧២ | កៅ ខេមរ៉ាន់ | ប | ១៩៥៦ | - | |
| ៧៣ | មាន ឌីរ៉ូ | ប | ១៩៥២ | - | |

| | | | | | |
|---|---|---|---|---|---|
| ៧៤ | នាង គឹមស៊ុន | ប | ១៩៥៩ | បុគ្គលិក | |
| ៧៥ | សោម ធារី | ស | ១៩៦៩ | - | |
| ៧៦ | ប្រាក់ ម៉ាលើរំលោត | ស | ១៩៦៧ | - | |
| ៧៧ | កុល កុសល | ប | ១៩៥៨ | - | |
| ៧៨ | សុក មករា | ប | ១៩៦៨ | - | |
| ៧៩ | ស្វាយ យុទ្ធារី | ស | ១៩៦៦ | បុគ្គលិក | |
| ៨០ | ចៅ ប្រាង្គសុវណ្ណ | ប | ១៩៦៦ | - | |
| ៨១ | ជា រ៉ាន់ដេត | ប | ១៩៦៦ | - | |
| ៨២ | អ៊ុំ ពិសិដ្ឋ | ប | ១៩៦៦ | - | |
| ៨៣ | ហុក គឹមអ៊ាង | ប | ១៩៦៦ | បុគ្គលិក | |
| ៨៤ | ណៅ ប៊ុនធឿន | ប | ១៩៦៤ | - | |
| ៨៥ | អ៊ុម វាសនា | ប | ១៩៥៥ | - | |
| ៨៦ | អ៊ូ សុជីវី | ប | ១៩៦៨ | - | |
| ៨៧ | ម៉ី ចិត្រា | ប | ១៩៦៣ | - | |
| ៨៨ | វុធ ស៊ុរ៉ែន | ប | ១៩៦៩ | - | |
| ៨៩ | គុជ បួរ | ប | ១៩៤៦ | - | |
| ៩០ | កែវ ឈាង | ប | ១៩៥១ | - | |
| ៩១ | ទុយ សាវឿន | ប | ១៩៤៤ | - | |
| ៩២ | ម៉ៅ ផុនសុន | ប | ១៩៥៤ | - | |
| ៩៣ | សរ សុវណ្ណា | ប | ១៩៦៨ | - | |
| ៩៤ | អ៊ុន គឹមហួត | ប | ១៩៤៣ | - | |
| ៩៥ | តែ អេង | ប | ១៩៥២ | - | |
| ៩៦ | នៃ មាន | ប | ១៩៤៤ | - | |
| ៩៧ | នៅ ស៊ីផុន | ប | ១៩៥០ | - | |
| ៩៨ | អ៊ុំ រុន | ប | ១៩៤៥ | - | |
| ៩៩ | សែម វៃ | ប | ១៩៦៧ | - | |
| ១០០ | ជុំ សការ៉ុន | ប | ១៩៥៩ | - | |
| ១០១ | ឈុំ ស៊ីផាន់ | ប | ១៩៦៧ | - | |
| ១០២ | សាយ និដ្ឋា | ប | ១៩៧៣ | - | |
| ១០៣ | ហ៊ី សាយ | ប | ១៩៧២ | - | |
| ១០៤ | តែ ប៊ូ | ប | ១៩៥០ | ប្រធានការិយាល័យ | |

| | | | | | |
|---|---|---|---|---|---|
| ១០៥ | ហ៊ើម សាមីឌី | ប | ១៩៦៧ | អនុប្រធានការិយាល័យ | |
| ១០៦ | ស៊ី វណ្ណា | ស | ១៩៥៣ | បុគ្គលិក | |
| ១០៧ | សំ គូរ៉ា | ស | ១៩៥៨ | - | |
| ១០៨ | សាម៉េត បូរាមី | ប | ១៩៦៩ | - | |
| ១០៩ | អ៊ុង បូរិនរិទ្ធ | ប | ១៩៦៥ | - | |
| ១១០ | មួល ណារិន | ប | ១៩៦៩ | បុគ្គលិក | |
| ១១១ | ប្អូន ប៊ុនណាន | ប | ១៩៦៧ | - | |
| ១១២ | អាស ណារឿន | ប | ១៩៥៤ | - | |
| ១១៣ | ជ៉ាវ វី | ស | ១៩៦៨ | បុគ្គលិក | |
| ១១៤ | ស៊ុំ អិន្ទារ៉ា | ប | ១៩៦៨ | - | |
| ១១៥ | លេង តាន់ធាង | ប | ១៩៦០ | - | |
| ១១៦ | សោង សុខដារ៉ុ | ប | ១៩៦៦ | - | |
| ១១៧ | បេន សុត្ថារុធ | ប | ១៩៦៤ | - | |
| ១១៨ | តូវ សុទ្រី | ប | ១៩៦៧ | - | |
| ១១៩ | ភឹម ភិរុណ | ប | ១៩៦៩ | - | |
| ១២០ | ស្រី សុផល | ស | ១៩៦១ | ប្រធានការិយាល័យ | |
| ១២១ | មាស វណ្ណា | ប | ១៩៥១ | អនុប្រធានការិយាល័យ | |
| ១២២ | អ៊ូ ធីរម្យ | ប | ១៩៦៧ | បុគ្គលិក | |
| ១២៣ | ចាន់ សុវណ្ណារិទ្ធ | ប | ១៩៦៧ | - | |
| ១២៤ | ទី ឈូរី | ប | ១៩៦៩ | - | |
| ១២៥ | ហៀង រត្នសុខា | ប | ១៩៧០ | - | |
| ១២៦ | ទូច ខាន់ដា | ប | ១៩៧០ | - | |
| ១២៧ | ណេរុន ទ្រី | ប | ១៩៦៥ | - | |
| ១២៨ | សុត ទ្រី | ប | ១៩៦៧ | - | |
| ១២៩ | អ៊ុង កែវចិន្តា | ប | ១៩៦៨ | - | |
| ១៣០ | ប៉ោ តុង | ប | ១៩៧០ | - | |
| ១៣១ | ហេង ផាត | ប | ១៩៦៧ | - | |
| ១៣២ | ភ័ន់ ណេរិន | ប | ១៩៥៦ | - | |
| ១៣៣ | ហ៊ៅ ប៊ុនវណ្ណៈ | ប | ១៩៧១ | - | |
| ១៣៤ | នាង សុជីវី | ប | ១៩៧២ | - | |
| ១៣៥ | អ៊ុក សុថា | ប | ១៩៦៩ | - | |

| | | | | |
|---|---|---|---|---|
| ១៣៦ | ហ៊ាន កុសល | ប | ១៩៥៩ | ប្រធានការិយាល័យ |
| ១៣៧ | អ៊ិន ធិតា | ស | ១៩៦២ | អនុប្រធានការិយាល័យ |
| ១៣៨ | ធូ សុខកោសល្យ | ប | ១៩៦២ | បុគ្គលិក |
| ១៣៩ | ហ៊ឹម ឃុនប៉ូឡា | ស | ១៩៦៥ | - |
| ១៤០ | ភុល ភីរម្យ | ប | ១៩៧០ | - |
| ១៤១ | ហ៊ៀល ម៉ូដេត | ប | ១៩៧១ | បុគ្គលិក |
| ១៤២ | អ៊ឹង លឹមម៉ាយូមី | ស | ១៩៦៧ | - |
| ១៤៣ | យ៉ាញ់ ភ័ណា | ស | ១៩៦២ | បុគ្គលិក |
| ១៤៤ | បេ សុខឡេង | ប | ១៩៧៣ | - |
| ១៤៥ | ប៉ុល មុទិតា | ប | ១៩៧០ | - |
| ១៤៦ | ចក់ សុប្រកាស | ប | ១៩៧០ | - |
| ១៤៧ | ម៉ៅ ប៊ុនស៊ីវ | ប | ១៩៥៧ | - |
| ១៤៨ | ប៉ែន ពៅ | ប | ១៩៧១ | - |
| ១៤៩ | ឈឹម ផាន | ប | ១៩៦៨ | - |
| ១៥០ | ម៉ិច ផាត់ចំណុច | ប | ១៩៧០ | - |
| ១៥១ | កឹម សាវ៉េត | ប | ១៩៦២ | - |
| ១៥២ | យស់ ផល្លី | ស | ១៩៦៨ | - |
| ១៥៣ | ដួន ចន្ថា | ប | ១៩៦៨ | - |
| ១៥៤ | ពែម ឡី | ប | ១៩៦៤ | - |
| ១៥៥ | ម៉ក់ អនណារិទ្ធ | ប | ១៩៥៦ | - |
| ១៥៦ | ចំរើន ប៉ូឡូ | ប | ១៩៧០ | - |
| ១៥៧ | ចៅ ប្រាង្គសុយន្តដា | ប | ១៩៧២ | - |
| ១៥៨ | កែវ ឡៃរចនា | ប | ១៩៧១ | - |
| ១៥៩ | ស៊ឹម សុផល | ប | ១៩៦៦ | - |
| ១៦០ | ថេង ស៊ីឡេន | ប | ១៩៦៨ | - |
| ១៦១ | ព្រំ គន្ធា | ស | ១៩៧០ | - |
| ១៦២ | ឃឹម ចំរើន | ប | ១៩៧០ | - |
| ១៦៣ | ឈ ប៊ុនឆេង | ប | ១៩៧០ | - |
| ១៦៤ | អេង ច័ន្ទធីរី | ស | ១៩៦២ | ប្រធានការិយាល័យ |
| ១៦៥ | ស្រី សម | ប | ១៩៥៤ | អនុប្រធានការិយាល័យ |
| ១៦៦ | ង៉ែត ប៊ុនថន | ប | ១៩៦៦ | បុគ្គលិក |

| | | | | | |
|---|---|---|---|---|---|
| ១៦៧ | បេងហុង សុជាតិខេមរ៉ូ | ប | ១៩៦៩ | បុគ្គលិក | |
| ១៦៨ | [illegible] | ប | ១៩៦៨ | - | |
| ១៦៩ | គីម ផាណ្ណារ៉េត | ប | ១៩៦០ | - | |
| ១៧០ | ម៉ឹង វុធ | ប | ១៩៦៧ | - | |
| ១៧១ | ទៀង សិទ្ធិ | ប | ១៩៦៩ | - | |
| ១៧២ | ប៊ូ វិច្ឆិកា | ស | ១៩៦៨ | បុគ្គលិក | |
| ១៧៣ | ណុណ សុខស្ទូឡ | ប | ១៩៦៧ | - | |
| ១៧៤ | អេង សេរីវុធ | ប | ១៩៥៣ | - | |
| ១៧៥ | ហ៊ត រ៉ុង | ប | ១៩៦៥ | - | |
| ១៧៦ | ណោ សុរះសិទ្ធ | ប | ១៩៦៦ | - | |
| ១៧៧ | អៀង រស្មីជាតិ | ប | ១៩៧៥ | - | |
| ១៧៨ | ណេត រ៉ុ | ប | ១៩៦៦ | - | |
| ១៧៩ | សុខ កណ្ណិកា | ប | ១៩៧០ | - | |
| ១៨០ | ឯម សុគន្ធ | ប | ១៩៦៩ | - | |
| ១៨១ | ប៉ែន ឫទ្ធី | ប | ១៩៦៧ | - | |
| ១៨២ | ហ៊ឹម សំអុល | ប | ១៩៧២ | - | |
| ១៨៣ | បេងហុង សុជាតិផារីដ | ប | ១៩៧២ | - | |
| ១៨៤ | សរ សារ៉ានី | ប | ១៩៦៧ | - | |
| ១៨៥ | ឡូ សិរីឿន | ប | ១៩៧០ | - | |
| ១៨៦ | ឡឹក ចិន្តា | ប | ១៩៦៨ | - | |
| ១៨៧ | អ៊ូ វណ្ណារ៉ា | ស | ១៩៧០ | - | |
| ១៨៨ | អោម វុត្ថា | ស | ១៩៧៣ | - | |
| ១៨៩ | ប៊ុង ចារិទ្ធ | ប | ១៩៧១ | - | |
| ១៩០ | ប៉ែន សុផល | ប | ១៩៧០ | - | |
| ១៩១ | រ៉ុត ដារ៉ា | ប | ១៩៦៨ | - | |
| ១៩២ | ញ៉ៀម សុខូ | ប | ១៩៧០ | - | |
| ១៩៣ | ទន្លាប់ ណុន | ប | ១៩៥៤ | ប្រធានការិយាល័យ | |
| ១៩៤ | សំ សារឿន | ប | ១៩៥៧ | អនុប្រធានការិយាល័យ | |
| ១៩៥ | សារិន វណ្ណា | ប | ១៩៦៩ | បុគ្គលិក | |
| ១៩៦ | ម៉ុម ថាណេត | ប | ១៩៦៩ | - | |
| ១៩៧ | វង្សី វិចិត្រ | ប | ១៩៦៨ | - | |

| | | | | | |
|---|---|---|---|---|---|
| ១៩៨ | កៅ សូផាត | ស | ១៩៦៨ | បុគ្គលិក | |
| ១៩៩ | ឈិន សារ៉ាន់ | ប | ១៩៥២ | - | |
| ២០០ | ប្រាក់ ច័ន្ទបញា | ប | ១៩៦៩ | - | |
| ២១០ | ឃស់ វណ្ណា | ប | ១៩៦៩ | - | |
| ២០២ | កុល សារាននួ | ប | ១៩៦១ | - | |
| ២០៣ | សៀវត សឿន | ប | ១៩៧៤ | បុគ្គលិក | |
| ២០៤ | មុត សុភាព | ស | ១៩៧៥ | - | |
| ២០៥ | ជា ស្រ៊ុន | ប | ១៩៥៥ | - | |
| ២០៦ | ឈ្លោក ប៉េងហុង | ប | ១៩៦៨ | - | |
| ២០៧ | ឥន ឆឺ | ប | ១៩៦៦ | - | |
| ២០៨ | ស៊ុន ហួត | ប | ១៩៧២ | - | |
| ២០៩ | ហេង សុខរិទ្ធី | ប | ១៩៧០ | - | |
| ២១០ | ឌី ឈុនហុក | ប | ១៩៧០ | - | |
| ២១១ | ស បំណង | ប | ១៩៦១ | ប្រធានការិយាល័យ | |
| ២១២ | ទិន សារាទិត | ប | ១៩៥៨ | អនុប្រធានការិយាល័យ | |
| ២១៣ | អំ ប៊ុនលី | ប | ១៩៥៩ | បុគ្គលិក | |
| ២១៤ | ស៊ឹង សុច្ចរ៉ា | ប | ១៩៦៦ | - | |
| ២១៥ | ទេព សុខា | ស | ១៩៥៩ | - | |
| ២១៦ | ហេង គ្រីន | ប | ១៩៥៨ | - | |
| ២១៧ | សុទ្ធ វណ្ណា | ស | ១៩៧០ | - | |
| ២១៨ | ស៊ីវ រដ្ឋា | ប | ១៩៧៣ | - | |
| ២១៩ | ឈុន វុឌ្ឍី | ប | ១៩៧៥ | - | |
| ២២០ | ឃ្លោក វុឌ្ឍនី | ប | ១៩៦៩ | - | |
| ២២១ | ព្រុំ សារ៉ាន្ត | ប | ១៩៦៨ | - | |
| ២២២ | ហែម សីហា | ប | ១៩៧២ | - | |
| ២២៣ | ណាំ វុទ្ធី | ប | ១៩៧៤ | - | |
| ២២៤ | កែវ សុវណ្ណារិទ្ធ | ប | ១៩៦៩ | - | |
| ២២៥ | មាស សុវណ្ណ | ប | ១៩៦១ | - | |
| ២២៦ | ទូស សាផាន់ | ប | ១៩៦៩ | - | |
| ២២៧ | សេក ស៊ុនវ៉ាន់ឌី | ប | ១៩៦៩ | - | |
| ២២៨ | ស លក្ខិណា | ស | ១៩៥៦ | - | |
| ២២៩ | ហង្ស សុតសំភារ | ប | ១៩៧២ | - | |
| ២៣០ | ឡៅ ទិព្វសីហា | ប | ១៩៧១ | - | |

| | | | | | |
|---|---|---|---|---|---|
| ២៣១ | សួង សំបូរខេមរ៉ា | ប | ១៩៥៦ | ប្រធានការិយាល័យ | |
| ២៣២ | ឆាយ សុខុន | ប | ១៩៦៦ | អនុប្រធានការិយាល័យ | |
| ២៣៣ | ទែន សំអុល | ប | ១៩៥៤ | បុគ្គលិក | |
| ២៣៤ | នួន សុផុន | ប | ១៩៦៨ | បុគ្គលិក | |
| ២៣៥ | ប្រាក់ សុជិន | ប | ១៩៧៥ | - | |
| ២៣៦ | សារ៉េ សុខដុម | ប | ១៩៥៤ | - | |
| ២៣៧ | ញ៉ុង វណ្ណៈរ៉េត | ប | ១៩៧៤ | - | |
| ២៣៨ | ហួត សេង | ប | ១៩៧៣ | - | |
| ២៣៩ | លេងហុង សុជាតិសីលា | ប | ១៩៧១ | - | |
| ២៤០ | ហេង ពីកាណ្ណាភក់ | ប | ១៩៧២ | - | |
| ២៤១ | តឹក ផ្ទួរសុខារីន | ប | ១៧៦៧ | - | |
| ២៤២ | មាស សុការ៉ារិទ្ធ | ប | ១៩៧០ | - | |
| ២៤៣ | ប៉ោយ ប៊ូណេ | ប | ១៩៧៥ | - | |
| ២៤៤ | បាន សុម៉ារ៉ា | ប | ១៩៧០ | - | |
| ២៤៥ | ទៀ ប៊ុនណារ៉ា | ប | ១៩៧២ | - | |
| ២៤៦ | ជួប សាត | ប | ១៩៦០ | - | |
| ២៤៧ | មុិញ ស៊ីថាយ | ប | ១៩៧៥ | - | |
| ២៤៨ | អ៊ុក មករាវុធ | ប | ១៩៧៤ | - | |
| ២៤៩ | លឹម លាងអាន | ប | ១៩៧៣ | - | |
| ២៥០ | គឹម ថៃ | ប | ១៩៧៤ | - | |
| ២៥១ | កង គឹមលុច | ប | ១៩៧១ | - | |
| ២៥២ | កាក់ វិបុលធារា | ប | ១៩៧២ | - | |
| ២៥៣ | ខុន ហួរ | ប | ១៩៧០ | - | |
| ២៥៤ | ជា វង្សចិន្តា | ប | ១៩៦៧ | - | |
| ២៥៥ | ដែង វណ្ណៈ | ប | ១៩៧១ | - | |
| ២៥៦ | លឹម សាវុឌ្ឍ | ប | ១៩៧២ | - | |
| ២៥៧ | ស ស៊ុណាត | ប | ១៩៧៣ | - | |
| ២៥៨ | សុន សុមាណ្ណារៈ | ប | ១៩៦៦ | - | |
| ២៥៩ | សៅ សេដ្ឋា | ប | ១៩៧២ | - | |
| ២៦០ | សៀប សិទ្ធិសេរី | ប | ១៩៧៣ | - | |
| ២៦១ | អ៊ឹង ស៊ីម៉ារ៉ូ | ប | ១៩៧០ | - | |
| ២៦១ | អ៊ិក សុខឡាយ | ប | ១៩៧៤ | - | |
| ២៦២ | អ៊ួ ណារិទ្ធ | ប | ១៩៧០ | បុគ្គលិក | |
| ២៦៣ | អ៊ីវ មុនី | ប | ១៩៥៦ | - | |

| | | | | | |
|---|---|---|---|---|---|
| ២៦៤ | មាស សម្បត្តិ | ប | ១៩៦៨ | បុគ្គលិក | |
| ២៦៦ | វង្ស វុទ្ធិ | ប | ១៩៧០ | - | |
| ២៦៧ | សំ ព្រហ្មនិត | ប | ១៩៧៥ | - | |
| ២៦៨ | នន់ រស្មី | ប | ១៩៧៦ | - | |
| ២៦៩ | នូ សុផាន់ | ប | ១៩៧៥ | - | |
| ២៧០ | វេង វាសនា | ប | ១៩៧៤ | - | |
| ២៧១ | ជួរ ជេតទីវន្ត | ប | ១៩៧៤ | - | |
| ២៧២ | ថោង ពិណា | ប | | - | |
| ២៧៣ | នូ វិនីតា | ប | ១៩៧៣ | - | |
| ២៧៤ | នួន សារ៉ូ | ប | ១៩៧១ | - | |

បញ្ឈប់បញ្ជីត្រឹមចំនួន ២៧៤ នាក់ ( ពីររយចិតសិបបួននាក់ )

ភ្នំពេញ,ថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៩៩

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

អ៊ឹម ឈុនលឹម

## ៥-ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន កីឡា

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៩

### ប្រកាសលេខ ៣៨២ អយក.ប្រក

### ស្តីពីការបើកសាលាបឋមសិក្សា " ភ្នំត្រយឹង "

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

***

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតស្នើសុំរបស់ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពត លេខ០៣ អយក.ខ.បឋ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ១៩៩៩

- តាមសំណើរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១ :** បើកសាលាបឋមសិក្សា ភ្នំត្រយឹង ដែលមានទីតាំងស្ថិតនៅ ឃុំ ល្អាង ស្រុកដងទង់ ខេត្តកំពត ជាសាលាបឋមសិក្សា ពេញលក្ខណៈចាប់ពីឆ្នាំសិក្សា ១៩៩៨-១៩៩៩ នេះតទៅ ។

**ប្រការ ២ :** សាលាបឋមសិក្សា ភ្នំត្រយឹង ត្រូវដឹកនាំដោយនាយកមួយរូប និងនាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

**ប្រការ ៣ :** នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ច តាមគោលការណ៍កំណត់របស់រដ្ឋ ។

**ប្រការ ៤ :** នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋមសិក្សា និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពត ការិយាល័យអប់រំ យុវជន និង កីឡា ស្រុកដងទង់ នាយកសាលាបឋមសិក្សា " ភ្នំត្រយឹង " មានភារកិច្ច អនុវត្តប្រកាសនេះ ។

ជ.ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

**អ៊ឹម សិទ្ធី**

★★★

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៩

## ប្រកាសលេខ ៣៨៣ អយក.ប្រក

### ស្តីពីការបើកសាលាបឋមសិក្សា " វត្តជ័យខ្ពស់ "

***

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតស្នើសុំរបស់ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពត លេខ០៣ អយក.ខ.បឋ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ១៩៩៩

- តាមយោបល់រួមគ្នារបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : បើកសាលាបឋមសិក្សា វត្តជ័យខ្ពស់ ដែលមានទីតាំងស្ថិតនៅ ឃុំ ដំណាក់កន្ទួតខាងត្បូង ស្រុកកំពង់ត្រាច ខេត្តកំពត ជា សាលាបឋមសិក្សា ពេញលក្ខណៈចាប់ពីឆ្នាំសិក្សា ១៩៩៨-១៩៩៩ នេះតទៅ ។

ប្រការ ២ : សាលាបឋមសិក្សា វត្តជ័យខ្ពស់ ត្រូវដឹកនាំដោយនាយកមួយរូប និងនាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

ប្រការ ៣ : នាយក នាយករង មានសិទ្ធិទទួលប្រាក់បំនាច់ភារកិច្ច តាមគោលការណ៍កំណត់របស់រដ្ឋ ។

ប្រការ ៤ : នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋមសិក្សា និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពត ការិយាល័យអប់រំ យុវជន និង កីឡា ស្រុកកំពង់ត្រាច នាយកសាលាបឋមសិក្សា " វត្តជ័យខ្ពស់ " មានភារកិច្ច អនុវត្តប្រកាសនេះ ។

ជ.ឧបនាយករដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា
រដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
អ៊ឹម សិទ្ធី

★★★

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៩

## ប្រកាសលេខ ៣៨៤ អយក.ប្រក

### ស្តីពីការបើកសាលាបឋមសិក្សា " ស្ពានជ្រាវ អេស ស៊ី ស៊ី "

***

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

- បានពិនិត្យលិខិតលេខ ២២៨ អយក.ស្រសរ.ចទម ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៨ របស់ប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុក សៀមរាប
- តាមសំណើរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : បើកសាលាបឋមសិក្សា ស្ពានជ្រាវ អេស ស៊ីស៊ី ដែលមានទីតាំងស្ថិតនៅឃុំ សៀមរាប ស្រុកសៀមរាប ខេត្តសៀមរាប ជា សាលាបឋមសិក្សា ពេញលក្ខណៈចាប់ពីឆ្នាំសិក្សា ១៩៩៨-១៩៩៩ នេះតទៅ ។

ប្រការ ២ : សាលាបឋមសិក្សា ស្ពានជ្រាវ អេស ស៊ីស៊ី ត្រូវដឹកនាំដោយនាយកមួយរូប និងនាយករង តាមការចាំបាច់ព្រមទាំងគ្រូបើកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

ប្រការ ៣ : នាយក នាយករង មានសិទ្ធិទទួលប្រាក់បំនាច់ភារកិច្ច តាមគោលការណ៍កំណត់របស់រដ្ឋ ។

ប្រការ ៤ : នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋមសិក្សា និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និងកីឡា ខេត្តសៀមរាប ការិយាល័យអប់រំ យុវជន និង កីឡា ស្រុកសៀមរាប នាយកសាលាបឋមសិក្សា " ស្ពានជ្រាវអេស ស៊ីស៊ី " មានភារកិច្ចអនុវត្តប្រកាសនេះ ។

ជ.ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងអប់រំ
រដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
អ៊ឹម សិទ្ធី

★★★

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៩

## ប្រកាសលេខ ៣៨៥ អយក.ប្រក

## ស្តីពីការផ្លាស់សាលាឧបសម្ព័ន្ធ " វត្តដំបូកខ្ពស់ " មកជាសាលាបឋមសិក្សា ពេញលក្ខណៈ

***

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតស្នើសុំរបស់សាលាក្រុង លេខ៣៨០៧ សេស.គរ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ១៩៩៧
- តាមសេចក្តីស្នើរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

សំរេច

**ប្រការ ១ :** ផ្លាច់សាលាឧបសម្ព័ន្ធ វត្តដំបូកខ្ពស់ ពីសាលាបឋមសិក្សា វត្តសន្សំកុសល ដែលមានទីតាំងស្ថិតនៅសង្កាត់បឹងទំពុន ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ មកជាសាលាបឋមសិក្សា ពេញលក្ខណៈវិញ ចាប់ពីឆ្នាំ សិក្សា ១៩៩៨-១៩៩៩ នេះតទៅ ។

**ប្រការ ២ :** សាលាបឋមសិក្សា វត្តដំបូកខ្ពស់ ត្រូវដឹកនាំដោយនាយកម្នាក់ និងនាយករង តាមការកំណត់ព្រមទាំងបុគ្គលិកផ្សេងៗ គ្រប់តាមមធ្យោបាយប្រាក់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

**ប្រការ ៣ :** នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ច តាមគោលការណ៍កំណត់របស់រដ្ឋ ។

**ប្រការ ៤ :** នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋមសិក្សា និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ ការិយាល័យអប់រំ យុវជន និង កីឡា ខ័ណ្ឌមានជ័យ នាយកសាលាបឋមសិក្សា " វត្តដំបូកខ្ពស់ " មានភារកិច្ចអនុវត្តប្រកាសនេះ ។

ជ.ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ
រដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
អ៊ឹម សិទ្ធី

★★★

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៩

## ប្រកាសលេខ ៣៨៦ អយក.ប្រក

## ស្តីពីការទទួលស្គាល់សាលាបឋមសិក្សា " សមាគមសង្គហៈស្ត្រីខ្មែរ "

***

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតស្នើសុំរបស់សមាគមសង្គហៈស្ត្រីខ្មែរ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ ១៩៩៧ តាមលោបល់យោបល់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១ :** ទទួលស្គាល់សាលាបឋមសិក្សា សមាគមសង្គហៈស្ត្រីខ្មែរ ដែលមានទីតាំងស្ថិតនៅក្នុងភូមិ សមាគមសាមគ្គីភាពឧដុង្គ ឃុំ វាលពង់ ស្រុកឧដុង្គ ខេត្ត កំពង់ស្ពឺ មកជាសាលាបឋមសិក្សាសាធារណៈ វិញ ចាប់ពីឆ្នាំ សិក្សា ១៩៩៨-១៩៩៩ នេះតទៅ ។

**ប្រការ ២ :** សាលាបឋមសិក្សា សមាគមសង្គហៈស្ត្រីខ្មែរ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ និង ត្រូវអនុវត្តកម្មវិធីសិក្សា និងសៀវភៅសិក្សាគ្រប់មុខវិជ្ជា តាមការអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**ប្រការ ៣ :** មន្ត្រីគ្រប់គ្រង គ្រប់លំដាប់ថ្នាក់ ក្នុងសាលាបឋមសិក្សា សមាគមសង្គហៈស្ត្រីខ្មែរ ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការក្របខ័ណ្ឌ ដើម្បីស្នើតែងតាំង ។

**ប្រការ ៤ :** នាយក នាយករង មានសិទ្ធិទទួលប្រាក់បំនាច់ភារកិច្ច តាមគោលការណ៍កំណត់របស់រដ្ឋ ។

**ប្រការ ៥ :** ចំណាយផ្សេងៗ ចំណាយសំរាប់បៀវត្ស និងប្រាក់ឧបត្ថម្ភមន្ត្រីរាជការ ក្របខ័ណ្ឌ ស្ថិតក្នុងថវិការបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ ចាប់ពីថ្ងៃចេញប្រកាសទទួលស្គាល់នេះ ។

**ប្រការ ៦ :** នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋមសិក្សា និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ស្ពឺ ការិយាល័យអប់រំ យុវជន និង កីឡា ស្រុកឧដុង្គ នាយកសាលាបឋមសិក្សា " សមាគមសង្គហៈស្ត្រីខ្មែរ " មានភារកិច្ច អនុវត្តប្រកាសនេះ ។

ជ.ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ
រដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
អ៊ឹម សិទ្ធី

★★★

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៩

# ប្រកាសលេខ ៣៨៧ អយក.ប្រក
## ស្តីពីការផ្លាស់សាលាអនុវិទ្យាល័យ " ហ៊ុន សែន កំពង់ត្របែក " មកជាសាលាវិទ្យាល័យ ពេញលក្ខណៈ

***

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតស្នើសុំរបស់ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង លេខ០៤ អយក.បវ.អ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៩៩
- តាមសេចក្តីស្នើរបស់នាយកដ្ឋានមធ្យម និង អគ្គាធិការសិក្សា

## សំរេច

**ប្រការ ១ :** ផ្លាស់សាលាអនុវិទ្យាល័យ ហ៊ុន សែន កំពង់ត្របែក ពីសាលាអនុវិទ្យាល័យ ព្រះសីហនុ ដែលមានទីតាំងស្ថិតនៅឃុំ កំពង់ត្របែក ស្រុក ស្វាយទៀប ខេត្តស្វាយរៀង មកជាសាលាវិទ្យាល័យ ពេញលក្ខណៈវិញចាប់ពីឆ្នាំ សិក្សា ១៩៩៨-១៩៩៩ នេះតទៅ ។

**ប្រការ ២ :** សាលាវិទ្យាល័យ ហ៊ុន សែន កំពង់ត្របែក ត្រូវដឹកនាំដោយនាយកមួយរូប និងនាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ត្រូវបានតែងតាំងនៅក្នុងក្របខ័ណ្ឌ សាលាវិទ្យាល័យ ។

**ប្រការ ៣ :** នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ច តាមគោលការណ៍កំណត់របស់រដ្ឋ ។

**ប្រការ ៤ :** នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានមធ្យមសិក្សា និង អគ្គាធិការសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និងកីឡា ខេត្តស្វាយរៀង ការិយាល័យអប់រំ យុវជន និង កីឡាស្រុកស្វាយទៀប នាយកសាលាវិទ្យាល័យ " ហ៊ុន សែន កំពង់ត្របែក " មានភារកិច្ចអនុវត្តប្រកាសនេះ ។

ជ.ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ
រដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
**អ៊ុម សំអុី**

# ៦-នីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៩៩

### ប្រកាសលេខ ១៩៣ អបស
### ស្តីពីការកំណត់តួនាទី ភារកិច្ចរបស់ក្រុមចត្តាឡីស័កនៅតាមច្រកទ្វារព្រំដែន

***

### ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរំសាយនិងបង្កើតទីស្នាក់ការត្រួតពិនិត្យតាមច្រកទ្វារព្រំដែន និង ផ្លូវគមនាគមន៍ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៩៧
- បានឃើញសេចក្តីជូនដំណឹងលេខ ៧៨៥ សជណ.អវ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៩៣ របស់រាជរដ្ឋាភិបាល ស្តីពីការដាក់អោយ មានដំណើរការត្រួតពិនិត្យចត្តាឡីស័កនៅតាមច្រកទ្វារព្រំដែនឡើងវិញ
- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល

### សំរេច

ប្រការ ១ : កំណត់តួនាទីនិង ភារកិច្ចឲ្យក្រុមចត្តាឡីស័កដែលជាការិយាល័យមួយស្ថិត នៅក្រោមឱវាទរបស់នាយកដ្ឋានការពារសុខភាពនៃអគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល ។

ក្រុមចត្តាឡីស័ក មានការិយាល័យកណ្តាលមួយនៅភ្នំពេញ និងផ្នែកក្រោមឱវាទមួយចំនួនប្រចាំការនៅគ្រប់ច្រកទ្វារព្រំដែនអន្តរជាតិ ។

ប្រការ ២ : គោលបំណងនៃការបង្កើត ក្រុមចត្តាឡីស័ក គឺ បង្ការនិងបង្ការជម្ងឺឆ្លងរាតត្បាតទាំងឡាយដែលអាចឆ្លងពីក្រៅប្រទេសមកក្នុងប្រទេស ឬ ពីក្នុងប្រទេស ទៅក្រៅប្រទេសវិញ ។

ប្រការ ៣ : ក្រុមចត្តាឡីស័កត្រូវអនុវត្តនូវភារកិច្ច :

៣-១-ត្រួតពិនិត្យសុខភាពអាកាសយានិក នាវិក និយោជិត និងអ្នកដំណើរអន្តរជាតិនៅពេលមកដល់ តាមរយៈការពិនិត្យទំរង់បែបបទ និងឯកសារផ្សេងៗ រួមមាន លិខិតប្រកាសសុខភាពផ្ទាល់ខ្លួន វិញ្ញាបនប័ត្រចាក់ថ្នាំបង្ការជម្ងឺឆ្លង ដែលចាំបាច់ ប្រកាសដោយអង្គការសុខភាពពិភពលោក ។

៣-២-ក្នុងករណីដែល អាកាសយានិក នាវិក និយោជិត ឬ អ្នកដំណើរអន្តរជាតិ មានជម្ងឺឆ្លង ឬ សង្ស័យថាមានជម្ងឺឆ្លង ចំពោះបទបញ្ញត្តិសុខាភិបាលអន្តរជាតិ ( International Health Regulation) កើតមានឡើងនៅលើមធ្យោបាយដឹកជញ្ជូននានា ដែលឆ្លងកាត់ព្រំដែននៃព្រះ-រាជាណាចក្រកម្ពុជា មន្ត្រីចត្តាឡីស័ក ត្រូវចាត់វិធានការសមស្របតាមលក្ខណៈ បច្ចេកទេស សុខាភិបាល ហើយត្រូវបញ្ជូនអ្នកជម្ងឺនោះទៅកាន់មន្ទីរពេទ្យ ដែលនៅជិតបំផុត ដើម្បីធ្វើការព្យាបាល និងដាក់អោយនៅដោយឡែក ( Isolation ) ជាបន្ទាន់ ។

៣-៣-នៅក្នុងតំបន់ប្រតិបត្តិការចត្តាឡីស័ករួមមាន អាកាសយានដ្ឋាន កំពង់ផែអន្តរជាតិធំៗ និងតំបន់ប្រជុំជននៅគ្រប់ ច្រកទ្វារចេញ ចូល តាមព្រំដែន នៃព្រះរាជាណាចក្រកម្ពុជា បើមានករណីរាតត្បាតនៃជម្ងឺឆ្លងណាមួយ មន្ត្រីចត្តាឡីស័កប្រចាំការនៅទីនោះ មានភារកិច្ចត្រួតពិនិត្យស្ថានភាពអនាម័យទូទៅ សភាពទឹក ចំណីអាហារ គ្រឿងឧបភោគបរិភោគដែលដាក់លក់ក្នុងអាជីវដ្ឋានក្នុងតំបន់នោះ ហើយត្រូវជូនព័ត៌មានបន្ទាន់ទៅមន្ទីរសុខាភិបាលមូលដ្ឋាន ។

៣-៤-ក្នុងករណីមានសាកសព ឬអដ្ឋិធាតុត្រូវដឹកឆ្លងដែនចេញពីព្រះរាជាណាចក្រកម្ពុជា មន្ត្រីចត្តាឡីស័កត្រូវ ត្រួតពិនិត្យស្ថានភាពអនាម័យ ដេចខ្ចប់ និង ឈ្លូសដែលដាក់សាកសពនោះ ព្រមទាំងចេញលិខិតអនុញ្ញាតអោយដឹកសាកសព ឬអដ្ឋិធាតុជូន ។ បើក្នុងករណីដឹកនាំចូល ត្រូវឆែកមើលលិខិតអនុញ្ញាត ពីប្រទេសដើម ។

៣-៥-ចំពោះមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ រួមមាន អាកាសយាន នាវា ទូក កាណូត រថភ្លើង រថយន្ត កុងតឺន័រ ឬ មធ្យោបាយផ្សេងៗទៀត នៅពេលឆ្លងកាត់ព្រំដែន ឬមកដល់អាកាសយានដ្ឋានកំពង់ផែ ស្ថានីយ៍ ឬចំណត មន្ត្រីចត្តាឡីស័ក ត្រូវឡើង ត្រួតពិនិត្យស្ថានភាពអនាម័យទូទៅលើមធ្យោបាយដឹកជញ្ជូននោះ និង បំពេញបែបបទ គ្រប់បែបយ៉ាងសំរាប់ការចូលចត ។ បើពិនិត្យទៅឃើញថា ពុំមានអនាម័យត្រឹមត្រូវទេ សមត្ថកិច្ចចត្តាឡីស័ក ត្រូវអនុវត្តនូវវិធានការសមស្របតាម លក្ខណៈបច្ចេកទេស សុខាភិបាល ។

៣-៦-ចំពោះនាវាអន្តរជាតិ មុននឹងអនុញ្ញាតអោយចូលចតដល់កំពង់ផែ ត្រូវចតនៅចំណុចស្ងួតដែលបានកំណត់ ហើយត្រូវបង្ហូតទង់ពណ៌លឿងឡើងជាសញ្ញា ស្នើសុំអោយមន្ត្រី ចត្តាឡីស័កឡើងត្រួតពិនិត្យមុនគេនូវស្ថានភាពអនាម័យទូទៅលើនាវា រកមើលសត្វកណ្ដុរ សត្វល្អិតផ្សេងៗ ដែលជាភ្នាក់ងារចម្លងជម្ងឺ មើលអាងស្តុកទឹក កន្លែងទុកដាក់ម្ហូបអាហារកន្លែងចំអិនអាហារ គ្រឿងឧបភោគ បរិភោគ និងប្រដាប់ប្រដារប្រើប្រាស់របស់ នាវិក និយោជិត និងអ្នកដំណើរអន្តរជាតិ ។

៣-៧-គ្រប់នាវាទាំងអស់ត្រូវមានលិខិតបទដ្ឋានបញ្ជាក់ពីសុខភាពមនុស្សនៅលើនាវា វិញ្ញាបនប័ត្រចាក់ថ្នាំបង្ការជម្ងឺឆ្លង វិញ្ញាបនប័ត្រកំចាត់សត្វកណ្ដុរ ឬលើកលែងការកំចាត់សត្វកណ្ដុរ វិញ្ញាបនប័ត្របាញ់ថ្នាំសម្លាប់មេរោគ ( Disinfection ) និងសម្លាប់ សត្វល្អិត ( Fumigation ) ព្រមទាំងលិខិតស្នាមផ្សេងៗ ទៀតដែលពាក់ព័ន្ធនឹងស្ថានភាពអនាម័យ លើនាវា ។ មន្ត្រីនៃស្ថាប័នដទៃអាចអនុញ្ញាតអោយឡើងលើនាវាបាន លុះត្រាតែនីតិវិធានការសុខាភិបាលត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ និងធានាបាននូវសុវត្ថិភាពនៅលើនាវានោះរួចសព្វគ្រប់ហើយសិន ។

៣-៨-មុនពេលដែលនាវាចាកចេញពីកំពង់ផែ មន្ត្រីចត្តាឡីស័កត្រូវត្រួតពិនិត្យស្ថានភាពអនាម័យទូទៅនៅលើនាវា ដើម្បីធានាសុវត្ថិភាពកុំអោយមានការឆ្លងជម្ងឺទៅក្រៅវិញ ដោយមានចេញវិញ្ញាបនប័ត្រជាសំគាល់សំរាប់ការចេញដំណើរ នៃនាវា ។

**ប្រការ ៤ :** រាល់ទំរង់ការទាំងអស់ ( Formalities ) សំរាប់ត្រួតពិនិត្យព័ត៌មានពាក់ព័ន្ធនឹងសុខភាពអាកាសយានិក នាវិក និយោជិត និងអ្នកដំណើរអន្តរជាតិ ត្រូវបានចែកជូនដល់អ្នកទាំងនោះអោយបំពេញដោយផ្ទាល់ដៃ រួចហើយមកប្រគល់ជូនមន្ត្រីចត្តាឡីស័កវិញ នៅពេលចូលមកដល់អាកាសយានដ្ឋាន កំពង់ផែ ស្ថានីយ៍ ឬ ចំណត ដើម្បីអោយសមត្ថភាពកិច្ចចត្តាឡីស័កត្រួតត្រាបាននូវបញ្ហាសុខភាព សុវត្ថិភាព និង អនាម័យរបស់អ្នកទាំងនោះ ។

**ប្រការ ៥ :** ម្ចាស់អាកាសយាន នាវា ទូក កាណូត រថភ្លើង រថយន្ត និងមធ្យោបាយដឹកជញ្ជូនផ្សេងៗទៀតព្រមទាំងអ្នកដំណើរអន្តរជាតិទាំងអស់ ទាំងនៅពេលចូល និង ចេញត្រូវអនុវត្តតាមប្រកាសនេះអោយបានម៉ឺងម៉ាត់ ដើម្បីទទួលបានប្រសិទ្ធភាពខ្ពស់ ។ ជនប្រព្រឹត្តល្មើសនឹង ត្រូវផ្តន្ទាទោស ពិន័យតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៦ :** រាល់បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ទុកជានិរាករណ៍ ។

**ប្រការ ៧ :** ខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គាធិការដ្ឋាន និងក្រុម ចត្តាឡីស័កត្រូវអនុវត្តតាមខ្លឹមសារ នៃប្រកាសនេះអោយមានប្រសិទ្ធភាពល្អ និង ទទួលខុសត្រូវ ខ្ពស់រៀងៗខ្លួន ។

**ប្រការ ៨ :** ប្រកាសនេះ មានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី

បានចុះហត្ថលេខា និងត្រា

ខេដូ ហុង ស៊ុនហួត

# ៧-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ៨០២ សសរ.មសក្រខ

## ស្តីពីការបែងចែកនិស្សិតចំនួន ៣ នាក់ ដែលទើបបញ្ចប់ការសិក្សាពីបរទេស

***

## រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/៩៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- យោងលិខិតលេខ ៣១៩ សជណ អវ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ១៩៩៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

## សំរេច

**ប្រការ ១ :** អ្នកបច្ចេកទេសថ្នាក់បណ្ឌិតវិទ្យាសាស្ត្រចំនួន ០១ នាក់ និងថ្នាក់ឧត្តមចំនួន ២ នាក់ ដែលបានបញ្ចប់ការសិក្សាពីបរទេស ត្រូវបានបែងចែកអោយទៅ បំរើការងារ នៅក្រសួង -ស្ថាប័ន មួយចំនួន ដូចខាងក្រោមនេះ :

| ល.រ | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃ ខែ ឆ្នាំ កំណើត | អង្គភាព ដើម | មុខជំនាញ បច្ចេកទេស | កំរិតបណ្តុះ បណ្តាល | កំរិត បៀវត្ស | អង្គភាពចូល បំរើការងារ | ប្រភពបណ្តុះ បណ្តាល |
|---|---|---|---|---|---|---|---|---|---|
| ១ | ផុន ប៊ុនថាល់ | ប | ៣-៩-៧១ | សិស្ស | នីតិសាស្ត្រ | ប.វិ.ទ្យា | ៩០% ខ ၊ ៤ | ក្រសួងមហាផ្ទៃ | រុស្ស៊ី |
| ២ | ឯក នារីរ័ត្ន | ស | ០១-៣-៦៩ | សិស្ស | វេជ្ជសាស្ត្រ ទូទៅ | ឧត្តម | ៩០% ខ ၊ ១ | ក្រសួងសុខា -ភិបាល | វៀតណាម |

ប្រការ ២ : ក្រសួង- ស្ថាប័នដែលពាក់ព័ន្ធ មានភារកិច្ចទទួលយកអ្នកបច្ចេកទេសទាំងនេះ ដើម្បីបំពេញការងារ អោយត្រូវ តាមមុខជំនាញ និង ផ្តល់ប្រាក់បៀវត្សជូនសាមីជន ចាប់ពីថ្ងៃដែលបានចូលបំពេញការងារជាផ្លូវការ ។

ប្រការ ៣ : សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ពេជ្រ ម៉ិនធិន

★★★

## ៨-នីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៩

### ប្រកាសលេខ ៦៦ ប្រកវវស.ប្

### ស្តីពីការតែងតាំងមន្ត្រីរាជការមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ក្រុងប៉ៃលិន

***

### រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- យោងតាមសំណើសុំតែងតាំងមន្ត្រីរាជការចំនួន ០៣នាក់ ជាប្រធានមន្ទីរ និងអនុប្រធានមន្ទីរ នៃមន្ទីរ វប្បធម៌ និងវិចិត្រសិល្បៈក្រុងប៉ៃលិន របស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងប៉ៃលិន

### សំរេច

ប្រការ ១ : ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន ០៣ ( បី ) នាក់ ដូចមានរាយនាមខាងក្រោមនេះ ជាប្រធានមន្ទីរ និង អនុប្រធានមន្ទីរ នៃមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈក្រុងប៉ៃលិន ក្រោមឱវាទក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ :

១- លោក លឹម ប៊ុនហេង ជាប្រធានមន្ទីរ

២- លោក អ៊ី លីឈុន ជាអនុប្រធានមន្ទីរ

៣- លោក ទង់ ទុតថា ជាអនុប្រធានមន្ទីរ

**ប្រការ ២ :** ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួន ត្រូវបានកែសម្រួលតាមតួនាទីភារកិច្ចថ្មី ។

**ប្រការ ៣ :** ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ក្រុងប៉ៃលិន និង សាមីខ្លួន មានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ព្រះរាជស្ថលេខា និងត្រា

**នរោត្តម បុប្ផាទេវី**

★★★